គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អូរ៉ូ ហ្វាយនែនខប ភីអិលស៊ី

ORO FINANCECORP PLC.



# របាយការណ៍ប្រចាំឆ្នាំ ២០២០

# មាតិកា


១. ទស្សនៈវិស័យ និងបេសកកម្ម ០១

២. កម្មវត្ថុអាជីវកម្ម ០២

៣. គុណតម្លៃរបស់យើង ០៣

៤. អំពីយើង ០៥

៥. របាយការណ៍ហិរញ្ញវត្ថុសង្ខេប ០៦

៦. ផលិតផលរបស់យើង ០៧

៧. សារពីនាយកប្រតិបត្តិ ០៩

៨. គណៈគ្រប់គ្រង ១១

៩. រចនាសម្ព័ន្ធគ្រប់គ្រង ១៥

១០. របាយការណ៍របស់គណៈគ្រប់គ្រង ១៨

១១. របាយការណ៍របស់សវនករឯករាជ្យ ២២

១២. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ២៧

១៣. របាយការណ៍ចំណូលពេញលេញ ២៨

១៤. របាយការណ៍បម្រែបម្រួលមូលធន ២៩

១៥. របាយការណ៍លំហូរសាច់ប្រាក់ ៣០

១៦. កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ ៣១

# ទស្សនៈវិស័យ និងបេសកកម្ម

## ទស្សនៈវិស័យ

អម្រ៉ូ ជាបណ្ដាញជាតិមួយនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក ដែលផ្ដល់ឲ្យប្រជាជនកម្ពុជា ដែលមានតម្រូវការហិរញ្ញវត្ថុដើម្បីយកទៅប្រើប្រាស់ក្នុងការទិញលំនៅឋានផ្ទាល់ខ្លួន។

## បេសកកម្ម

គាំទ្រប្រជាជនកម្ពុជាឱ្យទទួលបាននូវលំនៅឋានដែលមានគុណភាព និងមានជីវភាពរស់នៅល្អដែលប្រកបដោយស្ថិរភាព ភាពច្នៃប្រឌិត និងឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុរបស់អតិថិជន។ សំរេចនូវអភិបាលកិច្ចដែលមាន ស្តង់ដារល្អខ្ពស់បំផុត ការប្តេជ្ញាចិត្តដល់ភាគីពាក់ព័ន្ធទាំងអស់ អតិថិជន និងសហគមន៍ដែលគ្រឹះស្ថានបានបម្រើ។





# កម្មវត្ថុអាជីវកម្ម

" ដើម្បីក្លាយខ្លួនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេមួយ នៅកម្ពុជា ជាមួយនឹងភាពបត់បែន ព្រមទាំង សេវាកម្មដែលមានភាពប្រកួតប្រជែង ចំពោះអតិថិជន "

របាយការណ៍ ប្រចាំឆ្នាំ២០២០

# គុណតម្លៃរបស់យើង



### ការអនុវត្ត
អ្សូ៉ ព្យាយាមពុះពារជំនះរាល់ការលំបាក ដើម្បីសម្រេចបានសម្មិទ្ធិផលខ្ពស់។

### ការប្តេជ្ញាចិត្ត
អ្សូ៉ មានជំហររឹងមាំ និងការប្តេជ្ញាខ្ពស់ចំពោះភាគីពាក់ព័ន្ធទាំងអស់។

### ធនធានមនុស្ស
អ្សូ៉ នឹងបន្តអភិវឌ្ឍធនធានមនុស្សរបស់ខ្លួន។

### សុចរិតភាព
សុចរិតភាពគឺជាមូលដ្ឋានគ្រឹះរបស់ អ្សូ៉។

### ការធ្វើជាក្រុម
ក្រុមការងាររបស់អ្សូ៉ មានភាពស្វាហាប់ និងមានចលនាបត់បែនឆ្ពោះទៅមុខ
ទាំងអស់គ្នា ដើម្បីអនាគតដ៏ត្រចះត្រចង់របស់ អ្សូ៉។

# អំពីយើង

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **អរ្យូ ហ្វាយនែនខប ភីអិលស៊ី** ត្រូវបានបង្កើតជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតក្នុងប្រទេសកម្ពុជា នៅថ្ងៃ ០៤ ខែ មេសា ឆ្នាំ ២០១៣ ហើយបានទទួលបានអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពី**ធនាគារជាតិនៃកម្ពុជា** នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៣។ ពាក្យថា "**អរ្យូ**" គឺជាភាសាក្រិចដែលមានអត្ថន័យជាភាសាខ្មែរស្មើនឹង "**មាស**" ដែលនេះជានិមិត្តរូបនៃនិរន្តភាព និងភាពគង់វង្សយូរអង្វែងនៃជីវិតដ៏សម្បូររុងរឿងក្នុងការវិនិយោគ ឬអាជីវកម្ម។ អរ្យូ រំពឹងថានឹងអភិវឌ្ឍខ្លួនឱ្យក្លាយទៅជាគ្រឹះស្ថានដែលផ្ដល់សេវាហិរញ្ញវត្ថុឈាន មុខគេនៅកម្ពុជា។








# របាយការណ៍ហិរញ្ញវត្ថុសង្ខេប

**២០១៦**

សម្រៀតឥណទាន៖ USD ១៦.៦១១.៣៤១
ទ្រព្យសកម្មសរុប៖ USD ១៧.៩៦៨.៦២១
មូលនិធិផ្ទាល់សុទ្ធសរុប៖ USD ៧.៨៧៤.១៧២
ចំណូលការប្រាក់សុទ្ធ៖ USD ៣.៥៦៦.៩៤៨

**២០១៧**

សម្រៀតឥណទាន៖ USD ១១.២២៤.៣៩៣
ទ្រព្យសកម្មសរុប៖ USD ៩.៨៣៦.១៤៦
មូលនិធិផ្ទាល់សុទ្ធសរុប៖ USD ៥.៩៩៦.២៦៩
ចំណូលការប្រាក់សុទ្ធ៖ USD ១.៥៨៧.១៩៤

**២០១៨**

សម្រៀតឥណទាន៖ USD ១.៤៩២.០៨៣
ទ្រព្យសកម្មសរុប៖ USD ៦.២០៧.៣៩៥
មូលនិធិផ្ទាល់សុទ្ធសរុប៖ USD ៥.៦២៤.៥៩៣
ចំណូលការប្រាក់សុទ្ធ៖ USD ១.៦៧៣.១៤៩

**២០១៩**

សម្រៀតឥណទាន៖ USD ៤.៩៧៤.៩០៨
ទ្រព្យសកម្មសរុប៖ USD ៦.៦៩៨.៧៤០
មូលនិធិផ្ទាល់សុទ្ធសរុប៖ USD ៥.៧២៣.៩៤០
ចំណូលការប្រាក់សុទ្ធ៖ USD ៦៦១.៩១១

**២០២០**

សម្រៀតឥណទាន៖ USD ៣.៩៣៣.២៩៣
ទ្រព្យសកម្មសរុប៖ USD ៦.៥៤៧.៩៨៩
មូលនិធិផ្ទាល់សុទ្ធសរុប៖ USD ៥.២៨៤.៧៧៧
ចំណូលការប្រាក់សុទ្ធ៖ USD ៥៧២.៨៣៤

របាយការណ៍ ប្រចាំឆ្នាំ២០២០

# ផលិតផលរបស់យើង

## កម្ចីទិញផ្ទះ

បច្ចុប្បន្ននេះ អ្សូ៉ ផ្តោតទៅលើការផ្តល់កម្ចីទិញផ្ទះ សម្រាប់តែអតិថិជនដែលមានបំណងចង់ទិញ ឬ បានទិញផ្ទះនៅគម្រោងបុរីអារ៉ាតា ហ្គាដិន រ៉េស៊ីដិនស៍ បុរីមហាសែនសុខ និងគម្រោងអគារសហកម្មសិទ្ធិ បូដាយជូ រ៉េស៊ីដិនស៍ ដែលអ្សូ៉ បានសហការជាមួយតែប៉ុណ្ណោះ។ ក្នុងករណីអតិថិជនមិនមានប្រាក់គ្រប់គ្រាន់សម្រាប់ទិញផ្ទះនៅក្នុងគម្រោងខាងលើ អតិថិជនអាចដាក់ពាក្យស្នើសុំកម្ចីទិញផ្ទះពី អ្សូ៉ បាន។









របាយការណ៍ ប្រចាំឆ្នាំ២០២០

# សារពីនាយកប្រតិបត្តិ



**លោក EGUCHI TAKASHI**

**នាយកប្រតិបត្តិ**

២០២០ គឺជាឆ្នាំដែលមានភាពលំបាកបំផុត ព្រោះការរាតត្បាតជាសាកលនៃជំងឺកូវីដ- ១ ៩ បានជះឥទ្ធិពលគួរឱ្យកត់សម្គាល់ទៅលើសេដ្ឋកិច្ចជាសាកល រួមបញ្ចូលទាំងប្រទេសកម្ពុជាផងដែរ។ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានកត់ត្រានូវអត្រាកំណើនសេដ្ឋកិច្ចជាអវិជ្ជមាន ក្នុងឆ្នាំ ២០២០ ដែលនេះជាបទពិសោធន៍លើកទីមួយរបស់យើង ដែលយើងទទួលបានចាប់តាំងពីយើងចាប់ផ្តើមអាជីវកម្មរបស់យើងក្នុងឆ្នាំ២០១៣ ។ ជាលទ្ធផល ចំនួនឥណទានអាក្រក់ និងជាប់សង្ស័យនៃចំនួនឥណទានរបស់យើងសរុបទៅកាន់អតិថិជនបានកើនឡើងជាង ០២ ដងលើតួលេខនៅចុងឆ្នាំ ២០១៩ ខណៈពេលដែលចំនួនឥណទានរបស់យើងទៅកាន់អតិថិជនមានការថយចុះមកនៅ ៨០% នៃតួលេខនៅចុងឆ្នាំ ២០១៩ ហើយវាបណ្តាលឱ្យផលចំណេញរបស់យើង(មុនការបង់ពន្ធលើប្រាក់ចំណូល) ប្រែទៅជាអវិជ្ជមាន។

ក្នុងឆ្នាំ ២០២០ ដោយសារតែការរាតត្បាតជាសាកលបានជះឥទ្ធិពលលើសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ធនាគារជាតិនៃកម្ពុជាបានចាត់វិធានការណ៍សមរម្យជាច្រើន ដើម្បីកាត់បន្ថយភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋ ជាពិសេសទៅលើចំណូល និងជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជា។ ទោះបីជាយើងកំពុងតែជួបប្រទះជាមួយនឹងស្ថានភាពនេះក៏ដោយ ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា យើងបានព្យាយាមគាំទ្រអតិថិជន និងចូលរួមចំណែកដល់សេដ្ឋកិច្ចនៃប្រទេសកម្ពុជា តាមរយៈការធ្វើខ្លួនឱ្យស្របទៅតាមតម្រូវការនៃបទប្បញ្ញត្តិផ្សេងៗ។ យើងចាត់ទុកវាជាតួនាទីរបស់យើងក្នុងការធ្វើនិយតកម្ម ឱ្យស្របទៅតាមបរិយាកាសនៃបទប្បញ្ញត្តិថ្មីៗទាំងនេះ។ ដើម្បីឱ្យសមស្របជាមួយនឹងអនុសាសន៍របស់ធនាគារជាតិនៃកម្ពុជា និងភាពលំបាករបស់ប្រជាពលរដ្ឋ យើងបានរៀបចំគោលនយោបាយ និងនីតិវិធីចាំបាច់មួយចំនួន ដើម្បីសិក្សាពីកម្រិតនៃភាពលំបាករបស់ពួកគាត់ និងកម្រិតដែលយើងអាចជួយបាននៅក្នុងបរិបទនៃការពន្យាពេលទូទាត់ការបង់ប្រាក់ ការរៀបចំឥណទានសារឡើងវិញ និងការលើកលែងចំពោះប្រាក់ពិន័យលើទឹកប្រាក់ដែលយឺតយ៉ាវ។ ជាលទ្ធផល នាបំណាច់ឆ្នាំ២០២០ ៧,៤១% នៃឥណទានសរុបទៅកាន់អតិថិជន ត្រូវបានរៀបចំសារឡើងវិញ តាមសំណើពីសំណាក់អតិថិជន។

ម៉្យាងវិញទៀត យើងបានបោះជំហានឆ្ពោះទៅមុខទៀត ដោយចងក្រងរបាយការណ៍របស់ពួកយើង ជារបាយការណ៍រួមបញ្ចូលគ្រប់ព័ត៌មាននានា ពោលគឺយើងបានធ្វើការយកចិត្តទុកបន្ថែមលើរបាយការណ៍ប្រចាំឆ្នាំស្តីពីអនាគតក្រុមហ៊ុន ទាំងទិន្នន័យពាក់ព័ន្ធនឹងហិរញ្ញវត្ថុ និងមិនពាក់ព័ន្ធនឹងហិរញ្ញវត្ថុ។ ក្នុងឆ្នាំ ២០២០ យើងតែងតែបានជួបជាមួយភាគីពាក់ព័ន្ធ អតិថិជន វិនិយោគិន បុគ្គលិក ដើម្បីពិភាក្សាពីបញ្ហាទាំងពីរ គឺបញ្ហាស្តីពីយុទ្ធសាស្ត្រជាអាទិភាព និងបញ្ហាពាក់ព័ន្ធផ្សេងៗ ដែលមានសារៈសំខាន់ជូនដល់ពួកគេទាំងអស់គ្នា។ ការបោះជំហ៊ានក្នុងការរៀបចំរបាយការណ៍រួមបញ្ចូលគ្រប់ព័ត៌មាននានានេះ គឺស្របទៅតាមការដឹកនាំយើង ដើម្បីផ្តល់ជូននូវគុណតម្លៃរយៈពេលវែងសម្រាប់ភាគីពាក់ព័ន្ធទាំងអស់របស់យើង។

បច្ចុប្បន្ន យើងបានផ្តោតលើសេវាកម្មឥណទានលំនៅឋាន ដូចដែលបានបញ្ជាក់នៅក្នុងផ្នែកផលិតរបស់យើង។ យើងជឿជាក់ថាការកាន់កាប់អចលនទ្រព្យ (ផ្ទះ) ធ្វើឱ្យបុគ្គលនោះមានទ្រព្យសម្បត្តិ បើផ្តោតលើទិដ្ឋភាពហិរញ្ញវត្ថុ និងអាចធ្វើឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសជាតិដែលមានស្ថិរភាព និងភាពរឹងមាំ បើគិតចេញពីទិដ្ឋភាពហិរញ្ញវត្ថុ និងនយោបាយ។ យើងសប្បាយរីករាយក្នុងការគាំទ្រផ្នែកឥណទាន លំនៅឋានដល់បុគ្គលដើម្បីទិញផ្ទះ។ ជាមួយនឹងការប្តេជ្ញា និងការតាំងចិត្តរបស់ពួកគេ យើងមានទំនុកចិត្តថាយើងបានត្រៀមរួចរាល់ដើម្បីចាប់យកឱកាស និងបញ្ហាប្រឈមជាច្រើនដែលនឹងមកដល់នៅក្នុងពេលខាងមុខ។

ចុងក្រោយ យើងសូមសំដែងនូវកត្តញ្ញូភាព និងការដឹងគុណចំពោះធនាគារជាតិនៃកម្ពុជាចំពោះនិរន្តរភាពនៃការណែនាំ និងគាំទ្រ។ ខ្ញុំក៏សូមសំដែងនូវការដឹងគុណចំពោះអតិថិជន សម្រាប់ការជ្រើសរើសនូវសេវាកម្មរបស់យើង និងការគាំទ្រឥតឈប់ឈររបស់ពួកគេ។ បន្ថែមពីលើនេះទៀត ខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលិកទាំងអស់ចំពោះភក្តីភាព និងការខិតខំប្រឹងប្រែងឥតឈប់ឈររបស់ពួកគេ ក្នុងការធ្វើឱ្យប្រតិបត្តិការរបស់ក្រុមហ៊ុនមានភាពប្រសើរឡើង។ ជាមួយនឹងស្ថានភាពនាពេលបច្ចុប្បន្ន ជាពិសេសភាពមិនទៀងទាត់នៃការរាតត្បាតជាសាកល យើងនិងអតិថិជនរបស់យើងនៅតែប្រឈមនឹងស្ថានភាពលំបាកផ្សេងៗ។ យើងមានភាពជឿជាក់ថាយើងនឹងអាចឆ្លងកាត់ភាពលំបាកនេះជាមួយគ្នា ជាមួយនឹងការណែនាំ និងគាំទ្រពីធនាគារជាតិនៃកម្ពុជា ព្រមទាំងអតិថិជនដ៏មានតម្លៃ និងបុគ្គលិកដ៏ស្មោះត្រង់របស់យើង។

ដោយក្តីគោរពពីអ្នក



លោក EGUCHI TAKASHI

នាយកប្រតិបត្តិ

របាយការណ៍ ប្រចាំឆ្នាំ២០២០

# គណៈគ្រប់គ្រង



## លោក EGUCHI TAKASHI

នាយកប្រតិបត្តិ

ក្នុងនាមជានាយកប្រតិបត្តិ លោក Eguchi Takashi (លោក អ៊ីគូជី តាកាស៊ី) ទទួលខុសត្រូវទាំងស្រុងចំពោះ អាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំង ការអភិវឌ្ឍអាជីវកម្ម គ្រប់គ្រងការវិនិយោគនៅប្រទេសម៉ាឡេស៊ី មីយ៉ាន់ម៉ា ថៃ និង ឡាវ ដែលជាក្រុមហ៊ុនស្ថិតនៅក្រោម ក្រុមហ៊ុន គ្រីដគ្រុប ដែលជាម្ចាស់ ភាគហ៊ុនធំ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ្សូរ៉ូ ហ្វាយនែនខប ភីអិលស៊ី។

មុនពេលចូលបម្រើការងារ នៅក្រុមហ៊ុនគ្រីដគ្រុប នៅឆ្នាំ២០០៤ លោក Eguchi Takashi គឺជាអ្នកគ្រប់គ្រងទូទៅនៅសាជីវកម្មហិរញ្ញវត្ថុជប៉ុន ដែលជាគ្រឹះស្ថាន ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ទទួលខុសត្រូវផ្នែកផ្តល់កម្ចីទៅឱ្យក្រុមហ៊ុនតូចៗ និងមធ្យម និងធ្វើជាអ្នកឯកទេសស្រាវជ្រាវ នៅក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម ដែលលោកគឺជាអ្នកទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយសម្រាប់ក្រុមហ៊ុនតូច និងមធ្យម។

លោក Eguchi Takashi (លោក អ៊ីគូជី តាកាស៊ី) បានបញ្ចប់បរិញ្ញាប័ត្រពីសាកលវិទ្យាល័យតូក្យូ ប្រទេសជប៉ុនផ្នែកសេដ្ឋកិច្ច។



## កញ្ញា លាង ស្រីពៅ

ប្រធានគ្រប់គ្រងកិច្ចការ
អាជីវកម្មជាន់ខ្ពស់

ចាប់ពីខែ មករា ឆ្នាំ ២០២០ កញ្ញា លាង ស្រីពៅ ត្រូវបានតែងតាំងជាប្រធានគ្រប់គ្រងកិច្ចការអាជីវកម្មជាន់ខ្ពស់ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ្សូរ៉ូ ហ្វាយនែនខប ភីអិលស៊ី។ កញ្ញាគ្រប់គ្រងទៅលើប្រតិបត្តិការទាំងមូលរបស់គ្រឹះស្ថាន។ មុនពេលបម្រើការងារនៅគ្រឹះស្ថាន អ្សូរ៉ូ កញ្ញាមានបទពិសោធន៍ការងារក្នុងមុខតំណែងជា អ្នកគ្រប់គ្រង ជាង ១០ឆ្នាំក្នុងវិស័យផ្សេងៗដូចជា យុទ្ធសាស្ត្រសាជីវកម្ម ហិរញ្ញវត្ថុ គណនេយ្យ ច្បាប់ ធនធានមនុស្ស និងរដ្ឋបាល។

កញ្ញាបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន និងវគ្គសិក្សាមួយចំនួន ព្រមទាំងទទួលបានវិញ្ញាបនប័ត្រផ្នែករដ្ឋបាល និងលេខាធិការ លិខិតសរសើរពីសាលាភាសាបរទេសនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាខាទី២។

កញ្ញា បានបញ្ចប់បរិញ្ញាបត្រចំនួនពីរ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រងបរិញ្ញាបត្រផ្នែកគ្រប់គ្រង និងបរិញ្ញាបត្រគណនេយ្យ និងហិរញ្ញវត្ថុ។ កញ្ញាក៏បានបញ្ចប់វគ្គ សិក្សា ACCA ដោយប្រឡងជាប់វិញ្ញាសាវិជ្ជាជីវៈ និងជំនាញផ្នែករបាយការណ៍ សារជីវកម្មអន្តរជាតិ និងផ្នែកវិភាគអាជីវកម្ម និងទទួលបានសញ្ញាប័ត្រជំនាញ ពន្ធដារ នៅកម្ពុជាពីវិទ្យាស្ថាន CamEd Business School ផងដែរ។



## លោក សៀម សេងលី

ប្រធានផ្នែកគ្រប់គ្រង
ធនធានមនុស្ស

ចាប់ពីខែ សីហា ឆ្នាំ ២០១៩ លោក សៀម សេងលី ត្រូវបានតែងតាំងជាប្រធានគ្រប់គ្រងផ្នែករដ្ឋបាល និងធនធានមនុស្ស នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ្សូរ៉ូហ្វាយនែនខប ភីអិលស៊ី។ មុនពេលចាប់ផ្តើមការងារជាមួយ អ្សូរ៉ូ ហ្វាយនែនខប ភីអិលស៊ី លោក មានបទពិសោធន៍ផ្នែកធនធានមនុស្ស រដ្ឋបាល និង ប្រតិបត្តិច្បាប់ ជាមួយក្រុមហ៊ុនឯកជន និងអង្គការក្រៅរដ្ឋាភិបាល ដូចជា ក្រុមហ៊ុន ហ្វ្រែនធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិល ស៊ី អង្គការរ៉ាក់ អង្គការមូលនិធិកុមារកម្ពុជា ក្រុមហ៊ុនយ៉េរី អិចប្រេស (ខេមបូឌា) ឯ.ក និងក្រុមហ៊ុន តូរីយ៉ា អ៊ែរសេត ហូលឌីង ខូ អិលធីឌី។

លោក បានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ វេទមហាឫសី ទទួលបានបរិញ្ញាប័ត្រ គ្រប់គ្រងធនធានមនុស្ស។



## លោក ផុន ជាសុវណ្ណ

ប្រធានផ្នែកឥណទាន

ចាប់ពីខែ សីហា ឆ្នាំ ២០១៩ លោក ផុន ជាសុវណ្ណ ត្រូវបានតែងតាំងជាប្រធានផ្នែកឥណទាន នៅគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ អ្សូរ៉ូ ហ្វាយនែនខប ភីអិលស៊ី។ មុនពេលចូលបម្រើការងារនៅគ្រឹះស្ថាន អ្សូរ៉ូ លោកធ្លាប់ធ្វើជាបុគ្គលិកផ្នែកច្បាប់ និងអ្នកសម្របសម្រួលផ្នែកហិរញ្ញវត្ថុ នៅក្រុមហ៊ុនមរកតអន្តរជាតិគ្រុប និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមរកត ។ បន្ថែមពីនេះទៀតលោកធ្លាប់ជាប្រធានផ្នែកច្បាប់ នៅក្រុមហ៊ុន ម៉ាហា ហ្វេមីលី ប្រធីធី និងជាបុគ្គលិកផ្នែកច្បាប់ជាន់ខ្ពស់នៅ ក្រុមហ៊ុន Edotco (Cambodia) Co., Ltd.។

លោក ផុន ជាសុវណ្ណ បានបញ្ចប់បរិញ្ញាប័ត្រផ្នែកច្បាប់ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច និងបរិញ្ញាប័ត្រសេដ្ឋកិច្ច និងអភិវឌ្ឍជនបទ នៅសាកលវិទ្យាល័យមេគង្គកម្ពុជា និងបរិញ្ញាប័ត្រជាន់ខ្ពស់នីតិភូមិបាល និងបេតិកភណ្ឌ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច។

នៅចុងឆ្នាំ២០២០ លោក សុវណ្ណ ត្រូវបានអនុញ្ញាតអោយចូលប្រកបវិជ្ជាជីវៈមេធាវី ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

## លោកស្រី លីម វិច្ឆិការ

### ប្រធានផ្នែកសវនកម្មផ្ទៃក្នុង



លោកស្រី លីម វិច្ឆិការ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ក្នុងឆ្នាំ ២០១២។ បច្ចុប្បន្ននេះ លោកស្រីកំពុងបន្តវគ្គសិក្សា ACCA នៅសាលាពាណិជ្ជកម្ម ខេម អេដ ផងដែរ។ ការតែងតាំងរបស់លោកស្រីជាប្រធានសវនកម្មផ្ទៃក្នុងត្រូវបានទទួលការអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០២០។ មុនពេលតែងតាំងជាប្រធានសវនកម្មផ្ទៃក្នុង លោកស្រីត្រូវបានជ្រើសរើសជាប្រធានគណនេយ្យ នៅក្នុងក្រុមហ៊ុន តូរីយ៉ាអ៊ែរសេត ហូលឌីង ខូ អិលធីឌី នៅថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០១៩។

លោកស្រី បានចាប់ផ្តើមការងារដំបូងក្នុងតួនាទីជាសវនករផ្ទៃក្នុង នៅឆ្នាំ ២០១១ ជាមួយក្រុមហ៊ុន ជីអូលីង គ្រុប ខូ អិលធីឌី ហើយក្រោយមកគាត់បានផ្លាស់ទៅ ក្រុមហ៊ុន ប្រេគ្គន សនថុន (ខេមបូឌា) លីមីតធីត នៅឆ្នាំ២០១៦ ក្នុងតួនាទីជា ប្រធានក្រុមសវនករ។ ដោយការខិតខំប្រឹងប្រែង និងការអនុវត្តិរបស់លោកស្រី ធ្វើអោយគាត់ត្រូវបានតែងតាំងជាជំនួយការអ្នកគ្រប់គ្រងសវនកម្ម។ លោកស្រី មានបទពិសោធន៍សរុបនៅក្នុងក្រុមហ៊ុនសវនកម្មអន្តរជាតិជាង ០៣ ឆ្នាំ។

## លោក លាង ស៊ីណាន់

### ប្រធានផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ



ក្នុងខែសីហា ឆ្នាំ២០១៩ លោក លាង ស៊ីណាន់ ត្រូវបានតែងតាំងជាប្រធានផ្នែកគណនេយ្យនិងហិរញ្ញវត្ថុ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ៊ូរ៉ូ ហ្វាយនែនខប ភីអិលស៊ី ហើយគាត់ទទួលខុសត្រូវលើរាល់ប្រតិបត្តិការណ៍គណនេយ្យ និងហិរញ្ញវត្ថុ។ មុនពេលចាប់ផ្តើមជាមួយ អ៊ូរ៉ូ លោកជាគណនេយ្យករជាន់ខ្ពស់នៅក្រុមហ៊ុនគ្រីដគ្រុប។

លោក លាង ស៊ីណាន់ ទទួលបានបរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារពីសាកលវិទ្យាល័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយនឹងបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ នៅឆ្នាំ២០២១ ពីសាកលវិទ្យាល័យ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ គាត់បានបញ្ចប់វគ្គសិក្សាស្តីពីពន្ធដារនៅចុងឆ្នាំ២០១៩។ លើសពីនេះទៅទៀត លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាក់ទងនឹងស្តង់ដាររបាយការណ៍ ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពតូច និងមធ្យម (CIFRS for SMEs) និងរបៀបនៃការបំលែងរបាយការណ៍ ជាមួយស្ថាប័ន Quantum & Spectrum Solution Co., Ltd. និង 3S Consulting Co., Ltd.។



របាយការណ៍ ប្រចាំឆ្នាំ២០២០

## លោក សេង រ៉ូយ៉ាល់

### ប្រធានស្តីទីផ្នែកប្រតិបត្តិតាម



លោក សេង រ៉ូយ៉ាល់ មកពីខេត្តកំពង់ធំ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ ២០១៤ និងបរិញ្ញាប័ត្រផ្នែកសិល្បសាស្ត្រ ឯកទេសវិធីសាស្ត្របង្រៀនភាសាអង់គ្លេសពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ក្នុងឆ្នាំ ២០១៦។ បច្ចុប្បន្ន លោកកំពុងតែសិក្សាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកសិល្បសាស្ត្រ ឯកទេសវិធីសាស្ត្របង្រៀនភាសាអង់គ្លេស នៅវិទ្យាស្ថានភាសាបរទេស នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ចំពោះបទពិសោធន៍ការងាររបស់លោក លោក សេង រ៉ូយ៉ាល់ បានចាប់ផ្តើមពីបុគ្គលិកចុះកម្មសិក្សានៅសាលាឧទ្ធរណ៍ ក្នុងឆ្នាំ ២០២១ ហើយបន្ទាប់មកជាជំនួយការផ្នែកច្បាប់នៅ ការិយាល័យមេធាវី CSL & Associates ក្នុងឆ្នាំ ២០១៤។ លោកបានចាប់ផ្តើមការងារជាមួយនឹងក្រុមហ៊ុន តូរីយ៉ា អ៊ែរសេត ហូលឌីង ខូ អិលធីឌី ក្រោមដំណែង អនុប្រធានផ្នែកច្បាប់ ក្នុង ខែ មីនា ឆ្នាំ ២០១៨។ បច្ចុប្បន្ន លោកគឺជាប្រធានស្តីទីផ្នែកប្រតិបត្តិតាមនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ៊ូរ៉ូ ហ្វាយនែនខប ភីអិលស៊ី។ លោកគឺជាបេក្ខភាពដែលនឹងត្រូវបានតែងតាំងទៅកាន់ធនាគារជាតិ ដើម្បីស្នើសុំការអនុញ្ញាតជាផ្លូវការលើដំណែងមន្ត្រីប្រតិបត្តិតាម។

## កញ្ញា ទិន ដាវី

### ប្រធានប្រតិបត្តិការ



កញ្ញា ដាវី បញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យនៅសាកលវិទ្យាល័យន័រតុន។ បច្ចុប្បន្ន កញ្ញាកំពុងតែសិក្សាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កញ្ញាបានបម្រើការងារក្រោមតំណែងជាប្រធានប្រតិបត្តិ ការនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ៊ូរ៉ូ ហ្វាយនែនខប ភីអិលស៊ី ចាប់តាំងពីខែ កុម្ភៈ ឆ្នាំ ២០២០។

កញ្ញា បានចាប់ផ្តើមបម្រើការងារលើដំបូង ក្រោមតំណែងជាបញ្ជិកាគណនេយ្យករ នៅក្នុងក្រុមហ៊ុន ស្ទីល ប៊ីលឌីង ឯ.ក។ បន្ទាប់មក កញ្ញាបានបម្រើការងារជា គណនេយ្យករជាន់ខ្ពស់ផ្នែកចំណូល នៅក្នុងក្រុមហ៊ុន ជីលក្វ៉ាអ៊ែរសេត ហូលឌីង ខូ អិលធីឌី រយៈពេល ០៥ ឆ្នាំ។

# រចនាសម្ព័ន្ធគ្រប់គ្រង

- ម្ចាស់ភាគហ៊ុន
  - ក្រុមប្រឹក្សាភិបាល
    - គណៈកម្មការ ហានិភ័យ
    - គណៈកម្មការ សវនកម្ម
      - នាយកដ្ឋាន សវនកម្ម
        - ប្រធាននាយកដ្ឋាន សវនកម្ម — អ្នកនាង លឹម វិច្ឆិការ
    - នាយកប្រតិបត្តិ — លោក EGUCHI TAKASHI
      - ប្រធានគ្រប់គ្រង កិច្ចការអាជីវកម្មជាន់ខ្ពស់ — កញ្ញា លាង ស្រីពៅ
        - នាយកដ្ឋាន ច្បាប់ និងប្រតិបត្តិតាម
          - ប្រធាននាយកដ្ឋាន ច្បាប់ និងប្រតិបត្តិតាម — លោក អ៊ុំ វី
            - ប្រធាននាយកដ្ឋានរង ច្បាប់ និងប្រតិបត្តិតាម — លោក សេង វ៉ូយ៉ាល់
        - នាយកដ្ឋាន ធនធានមនុស្ស និងរដ្ឋបាល
          - ប្រធាននាយកដ្ឋាន ធនធានមនុស្ស និងរដ្ឋបាល — លោក សៀម សេងលី
        - នាយកដ្ឋាន គណនេយ្យ និងហិរញ្ញវត្ថុ នាយកដ្ឋាន ប្រតិបត្តិការ
          - ប្រធាននាយកដ្ឋាន គណនេយ្យ និងហិរញ្ញវត្ថុ — លោក លាង ស៊ីណាន់
            - មន្ត្រីផ្នែក គណនេយ្យ — លោក ស្រ៊ុយ គឹមឡៃ, លោក ខ ហេងហាក់; មន្ត្រីផ្នែក គណនេយ្យចំណូល — អ្នកនាង ទូច ភាព
            - ប្រធាន ប្រតិបត្តិការ — កញ្ញា វិន ដាវី
        - នាយកដ្ឋាន ឥណទាន
          - ប្រធាននាយកដ្ឋាន ឥណទាន — លោក ផុន ជាសុវណ្ណ







# របាយការណ៍របស់គណៈគ្រប់គ្រង

ក្រុមប្រឹក្សាភិបាល សូមដាក់ជូននូវរបាយការណ៍របស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ្សូ ហ្វាយនែនឧប ភីអិលស៊ី ("ក្រុមហ៊ុន") សម្រាប់ចុងការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ។

## ក្រុមហ៊ុន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ្សូ ហ្វាយនែនឧប ភីអិលស៊ី ("ក្រុមហ៊ុន") គឺជាស្ថាប័នមីក្រូហិរញ្ញវត្ថុដែលត្រូវបានបង្កើតឡើង និងចុះបញ្ជីនៅក្នុង ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនបានបង្កើតឡើង និងចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ជាមួយក្រសួងពាណិជ្ជកម្ម ក្រោមអាជ្ញាប័ណ្ណលេខ Co.0៦៥៣KH/២០១៣ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៣។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណជាស្ថាប័នមីក្រូហិរញ្ញវត្ថុពីធនាគារជាតិ នៃកម្ពុជា នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៣។ នាថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ ក្រុមហ៊ុនបានទទួលលេខចុះបញ្ជីពាណិជ្ជកម្មថ្មីលេខ០០០១៥៦៧៧ ពីក្រសួង ពាណិជ្ជកម្ម។

ការិយាល័យកណ្តាលរបស់ក្រុមហ៊ុនស្ថិតនៅផ្ទះលេខ១៤៧ មហាវិថីព្រះមុនីវ៉ង្ស សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនមានបុគ្គលិកចំនួន ១១នាក់ នាកាលបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩: ៦នាក់)។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺប្រតិបត្តិការសកម្មភាពមីក្រូហិរញ្ញវត្ថុ ដូចជាការផ្តល់សេវាកម្មឥណទាន ដោយអនុលោមតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា និងផ្តល់សេវាកម្មផ្សេងៗ ដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់ក្រុមហ៊ុន ដែលបានអនុម័តដោយធនាគារជាតិនៃកម្ពុជា ទៅឱ្យអតិថិជនក្នុងស្រុកតាមរយៈ ការិយាល័យកណ្តាលរបស់ខ្លួន នៅក្នុងរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ចុងការិយបរិច្ឆេទត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និង ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ មានដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| (ខាត)/ចំណេញ មុនបង់ពន្ធ | (៤៦៨.០៦៥) | (១.៩០៨.៣០១) | ១៨៥.៩៧១ | ៧៥៣.៥៥៤ |
| ពន្ធលើប្រាក់ចំណូល | ២៨.៩០២ | ១១៧.៨៣៣ | (៨៦.៦២៤) | (៣៥១.000) |
| (ខាត)/ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | (៤៣៩.១៦៣) | (១.៧៩០.៤៦៨) | ៩៩.៣៤៧ | ៤០២.៥៥៤ |

## ភាគលាភ

ពុំមានការប្រកាស ឬការបែងចែកភាគលាភ ហើយក្រុមប្រឹក្សាភិបាលក៏ពុំមានអនុសាសន៍ ឱ្យមានការបែងចែកភាគលាភ សម្រាប់ការិយបរិច្ឆេទនេះទេ។

## ដើមទុន

ពុំមានការប្រែប្រួលទៅលើដើមទុនដែលបានចុះបញ្ជី និងបោះផ្សាយរួចរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទនេះទេ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការផ្ទេរជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលមានការជឿជាក់ថារាល់ឥណទាន និងបុរេប្រទាន ដែលបានដឹងថាមិនអាចទារបាន ត្រូវបានលុបបំបាត់ចោល ហើយបានធ្វើសំវិធានធនគ្រប់គ្រាន់សម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីស្ថានភាពណាមួយដែលនឹងបណ្តាលឱ្យចំនួននៃការលុបបំបាត់ចោលឥណទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានចំនួនខ្វះខាតជាសារវន្តនោះឡើយ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយសន្និដ្ឋានថាមានតម្លៃមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឱ្យប៉ះពាល់ដល់ ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ដែលធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តន៍វិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំនូវទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ត្រូវបានធ្វើឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុនឡើយ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេលដប់ពីរខែបន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទដែលនឹងធ្វើឱ្យមានផលប៉ះពាល់ ឬអាចនឹង ប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់សងនោះទេ។

## ការប្រែប្រួលនៃសភាពការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញសភាពការណ៍ណាមួយដែលមិនបានវែកញែក នៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាល ឱ្យមានតួលេខនៃចំនួន ណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។





ក្រុមប្រឹក្សាភិបាលក៏មានមតិយោបល់ផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំ ឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទចេញរបាយការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានព្រឹត្តិការណ៍ណាមួយដែលកើតឡើងជាសារវន្តបន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទ ដែលតម្រូវឱ្យមានការធ្វើនិយ័តកម្ម និងត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននៅក្នុងឆ្នាំ និងនាកាលបរិច្ឆេទនៃការរបាយការណ៍នេះមានដូចខាងក្រោម៖

| ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទនៃការតែងតាំង |
|---|---|---|
| លោកស្រី សេង វ៉ាន់ថា | ប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៥ |
| លោក Tomohiro Yakushi | អភិបាល | ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៥ |
| លោក Toshihiko Muneyoshi | អភិបាល | ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៥ |
| លោក Eguchi Takashi | នាយកប្រតិបត្តិ | ថ្ងៃទី៤ ខែមិនា ឆ្នាំ២០២០ |

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់កាន់កាប់ ឬមានការទាក់ទិននៅក្នុងភាគហ៊ុនផ្ទាល់ ឬដោយប្រយោលរបស់ក្រុមហ៊ុននៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយ ដែលក្រុមហ៊ុនជាគូភាគីម្ខាង ដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ឱ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជា ការទិញភាគហ៊ុន ឬលិខិតបំណុលរបស់ក្រុមហ៊ុន ឬសាជីវកម្មដទៃទេ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមុន ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានទទួលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធមួយជាមួយនឹងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះ ជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះ ជាសមាជិកមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើនលើកលែងតែមានការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានការទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដើម្បីបង្ហាញពីទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុនាកាលបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទនេះ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

(ក) ជ្រើសរើសគោលនយោបាយគណនេយ្យ ឱ្យបានសមស្របដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រុងប្រយ័ត្ន ហើយបន្ទាប់មកធ្វើការអនុវត្តគោលនយោបាយទាំងនេះ ឱ្យមានសង្គតិភាព

(ខ) អនុលោមតាមបទប្បញ្ញត្តិរបស់ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់ សហគ្រាសខ្នាតតូចនិងមធ្យម និងសេចក្តីណែនាំដែលចេញដោយធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ហើយប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដារទាំងនេះ ក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណអោយបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការរបស់របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធនៃការគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព

(ឃ) ការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្មទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការ ក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចចិត្តសំខាន់ៗ ដែលប៉ះពាល់ដល់ប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមរាល់តម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំតំណាងឱ្យក្រុមប្រឹក្សាភិបាល សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយកំណត់សម្គាល់នានា បានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងលទ្ធផលប្រតិបត្តិការ និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ចុងការិយបរិច្ឆេទ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់ សហគ្រាសខ្នាតតូចនិងមធ្យម និងសេចក្តីណែនាំដែលចេញដោយធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ជំនួសឱ្យក្រុមប្រឹក្សាភិបាល

លោកស្រី សេង វ៉ាន់ថា
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១





# របាយការណ៍សវនករឯករាជ្យ

ហ្គ្រេន ថនថុន (ខេមបូឌា) លីមីតធីត
ជាន់ទី២០ អគារកាណាឌីយ៉ា ៣១៥ ផ្លូវព្រះអង្គឌួង
កែងមហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០
www.grantthornton.com.kh

**ជូនចំពោះក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អូរ៉ូ ហ្វាយនែនខប ភីអិលស៊ី**

## មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អូរ៉ូ ហ្វាយនែនខប ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនា ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ របាយកាណ៍ចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ នាចុងការិយបរិច្ឆេទ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ និងការពន្យល់ទៅលើពត៌មានផ្សេងៗ។

ជាមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុនា ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ចុងការិយបរិច្ឆេទ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម និងសេចក្តីណែនាំដែលចេញដោយធនាគារជាតិនៃកម្ពុជា។

## មូលដ្ឋាននៃមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ គឺត្រូវបានពិពណ៌នាបន្ថែមនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំប្រកាន់ខ្ជាប់នូវឯករាជ្យភាពពីក្រុមហ៊ុនដោយអនុលោមតាមស្តង់ដារនៃវិជ្ជាជីវៈគណនេយ្យអន្តរជាតិស្តីពីក្រមសីលធម៌របស់គណនេយ្យករជំនាញ (រួមជាមួយនឹង ស្តង់ដារឯករាជ្យភាពអន្តរជាតិ ដែលហៅកាត់ថា ("IESBA Code") ព្រមទាំង តម្រូវការក្រមសីលធម៌ដទៃទៀត ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាមក្រមសីលធម៌ផ្សេងទៀតស្របតាមតម្រូវការទាំងនោះ និងតាម IESBA Code។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មទាំងឡាយដែលយើងទទួលបានគឺគ្រប់គ្រាន់និងសមរម្យដើម្បីផ្តល់ជូនជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិរបស់យើងខ្ញុំ។

## ព័ត៌មានផ្សេងៗ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវទាំងស្រុងទៅលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមាន ព័ត៌មានដែលបានរៀបរាប់ក្នុងរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករយើងខ្ញុំឡើយ។ លើសពីនេះ វារួមបញ្ចូលផងដែរ នូវព័ត៌មានដែលយើងខ្ញុំទទួលបានមុនកាលបរិច្ឆេទរបាយការណ៍របស់សវនករ និងរបាយការណ៍ប្រចាំឆ្នាំត្រូវបានរំពឹងថា នឹងត្រូវបានផ្តល់អោយយើងខ្ញុំ បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍នេះ។

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗដែលរៀបចំដោយគណៈគ្រប់គ្រងនោះទេ ហើយយើងខ្ញុំក៏មិនបញ្ចេញមតិយោបល់ទៅលើព័ត៌មានទាំងនោះដែរ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗដែលបានបញ្ជាក់ខាងលើ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនសង្គតិភាពជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំដែលបានទទួលនៅពេលធ្វើសវនកម្ម ឬថាតើពត៌មានផ្សេងៗនេះបង្ហាញនូវកំហុសឆ្គងជាសារវន្តឬទេ។ ប្រសិនបើការអានព័ត៌មានផ្សេងៗនេះអាចឱ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តណាមួយពាក់ព័ន្ធនឹង របាយការណ៍ហិរញ្ញវត្ថុ ដែលយើងខ្ញុំបានទទួលមុនពេលចេញរបាយការណ៍របស់សវនករនេះ យើងខ្ញុំនឹងធ្វើការរាយការណ៍ទៅកាន់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានទាំងនេះឡើយ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានការរាយការណ៍ខុសជាសារវន្ត យើងខ្ញុំតម្រូវអោយរាយការណ៍បញ្ហាទាំងនោះទៅក្រុមប្រឹក្សាភិបាល និងឆ្លើយតបបញ្ហាផ្សេងៗ ដោយអនុលោមតាមតម្រូវការរបស់ CISA ៧២០ (បានកែប្រែ)។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូចនិងមធ្យម និងសេចក្តីណែនាំដែលចេញដោយធនាគារជាតិនៃកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមប្រឹក្សាភិបាលកំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវចំពោះការវាយតម្លៃសមត្ថភាពក្រុមហ៊ុនក្នុងការបន្តប្រតិបត្តិការដោយផ្អែកលើមូលដ្ឋាននិរន្តភាពត្រូវលាតត្រដាង ប្រសិនជាមានបញ្ហាទាក់ទងនឹងនិរន្តភាព និងប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តភាព លុះត្រាណាតែក្រុមប្រឹក្សាភិបាលមានគោលបំណងរំសាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការអាជីវកម្មតែម្តង។

## ការទទួលខុសត្រូវរបស់សវនករទៅលើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយបង្ហាញពីទិដ្ឋភាពពិត និងពុំមានលក្ខណៈខុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងនានា ក្នុងការធ្វើជាមូលដ្ឋាននៃការបញ្ចេញមតិយោបល់លើរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយដែលមានកម្រិតខ្ពស់ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា នឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលមានឡើយ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាមានលក្ខណៈជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើអោយប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្អែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងអនុវត្តនូវការវិនិច្ឆ័យ និងរក្សាមជ្ឈធាតុនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

ក) កំណត់ និង វាយតម្លៃ នូវហានិភ័យទាក់ទងនឹងការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គង ធ្វើការរៀបចំ និងអនុវត្តនិតិវិធីសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្ម ឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យបណ្តាលមកពីការរកមិនឃើញកំហុសជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងដោយអចេតនា។ ការក្លែងបន្លំរួមមាន ការឃុបគំនិត ការក្លែងបន្លំឯកសារ ការលុបចោលដោយចេតនា ការបង្ហាញខុស ឬ ការល្មើសទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។





ខ) ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនិតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។

គ) ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។

ឃ) ធ្វើការសន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់មូលដ្ឋាននិរន្តភាពគណនេយ្យរបស់ក្រុមប្រឹក្សាភិបាល ដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវន្តដែលអាចកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍នានា ឬលក្ខខណ្ឌផ្សេងទៀតដែលបណ្តាលឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពការបន្តនិរន្តភាពរបស់ក្រុមហ៊ុនឬទេ។ ប្រសិនបើយើងសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តណាមួយអាចនឹងកើតមានឡើង យើងតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ទាំងនោះក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍របស់ក្រុមប្រឹក្សាភិបាលទៅលើភាពមិនប្រក្រតីទាំងនោះ ឬក៏ប្រសិនបើការលាតត្រដាងនោះនៅមិនគ្រប់គ្រាន់ យើងខ្ញុំនឹងធ្វើការបញ្ចេញមតិយោបល់ថា របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមិនបានបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន គិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តភាពបាន។

ង) វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងការលាតត្រដាងនានាថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលទៅលើបញ្ហាផ្សេងៗ ទំហំការងារ និងពេលវេលាក្នុងការធ្វើសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងកង្វះខាតធំៗមួយចំនួន នៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលពួកយើងខ្ញុំរកឃើញអំឡុងពេលធ្វើសវនកម្ម។

យើងខ្ញុំក៏ផ្តល់ជូនក្រុមប្រឹក្សាភិបាលនូវសេចក្តីថ្លែងការណ៍មួយ ដែលយើងខ្ញុំបានអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ដែលទាក់ទងនឹងឯករាជ្យភាព ហើយយើងខ្ញុំធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលនូវបញ្ហាទាំងអស់ដែលនឹងគិតថាសមហេតុផលទៅលើឯករាជ្យភាពរបស់យើងខ្ញុំ និងការការពារដែលអាចមាន។

Grant Thornton

ហ្គ្រេន សនថុន (ខេមបូឌា) លីមីតធីត

គណនេយ្យករជំនាញ

សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera

នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១

# របាយការណ៍ហិរញ្ញវត្ថុ



# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | កំណត់សម្គាល់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
|---|---|---|---|---|---|
| ទ្រព្យសកម្ម | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៥ | ៧.១៥៧ | ២៨.៩៥០ | ១៥.១៩៤ | ៦១.៩១៦ |
| ប្រាក់បញ្ញើ និង ប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | ៦ | ៣៥៧.៥១៧ | ១.៤៤៦.១៥៦ | ៣៥៦.៥៤៣ | ១.៤៥២.៩១៣ |
| ប្រាក់បញ្ញើ និង ប្រាក់តម្កល់នៅធនាគារនានា | ៧ | ១.៦២១.២២០ | ៦.៥៥៧.៨៣៥ | ៤៩៣.៥៤៨ | ២.០១១.២០៨ |
| ឥណទានផ្ដល់ដល់អតិថិជន. សុទ្ធ | ៨ | ៣.៣០៤.០៥៦ | ១៣.៣៦៤.៩០៧ | ៤.៦៦៩.៧៨០ | ១៩.០២៩.៣៥៣ |
| ទ្រព្យសកម្មផ្សេងៗ | ៩ | ១.១៨៨.១៧៧ | ៤.៨០៦.១៧៦ | ១.១០៩.៦២២ | ៤.៥២១.៧១០ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១០ | ១.៣៥១ | ៥.៤៦៥ | ២.១៦៦ | ៨.៨២៦ |
| ទ្រព្យសកម្មអរូបិយ | ១១ | ១២.៦១៨ | ៥១.០៤០ | ២៦.២៥៦ | ១០៦.៩៩៣ |
| ពន្ធពន្យាទ្រព្យសកម្ម | ១២(ក) | ៥៥.៨៩៣ | ២២៦.០៨៧ | ២៥.៦៣១ | ១០៤.៤៤៦ |
| **ទ្រព្យសកម្មសរុប** | | **៦.៥៤៧.៩៨៩** | **២៦.៤៨៦.៦១៦** | **៦.៦៩៨.៧៤០** | **២៧.២៩៧.៣៦៥** |
| | | | | | |
| បំណុល និងមូលធន | | | | | |
| បំណុល | | | | | |
| បំណុលផ្សេងៗ | ១៣ | ១.២៦២.៤៤៥ | ៥.១០៦.៥៩០ | ៩០០.៤០៦ | ៣.៦៦៩.១៥៤ |
| ពន្ធលើប្រាក់ចំណូលត្រូវបង់ | ១២(ខ) | ៧៦៧ | ៣.១០៥ | ៧៤.៣៩៤ | ៣០៣.១៥៦ |
| **បំណុលសរុប** | | **១.២៦៣.២១២** | **៥.១០៩.៦៩៥** | **៩៧៤.៨០០** | **៣.៩៧២.៣១០** |
| | | | | | |
| មូលធន | | | | | |
| ដើមទុន | ១៤ | ៧.០០០.០០០ | ២៨.១២៦.០០០ | ៧.០០០.០០០ | ២៨.១២៦.០០០ |
| ខាតបង្គរ | | (១.៧១៥.២២៣) | (៦.៩១៤.២៩៩) | (១.២៧៦.០៦០) | (៥.១២៣.៨៣១) |
| លម្អៀងពីការប្ដូររូបិយប័ណ្ណ | | - | ១៦៥.២២០ | - | ៣២២.៨៨៦ |
| **មូលធនសរុប** | | **៥.២៨៤.៧៧៧** | **២១.៣៧៦.៩២១** | **៥.៧២៣.៩៤០** | **២៣.៣២៥.០៥៥** |
| **បំណុល និង មូលធនសរុប** | | **៦.៥៤៧.៩៨៩** | **២៦.៤៨៦.៦១៦** | **៦.៦៩៨.៧៤០** | **២៧.២៩៧.៣៦៥** |





# របាយការណ៍ចំណូលពេញលេញ

| | កំណត់សម្គាល់ | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដុល្លារអាមេរិក | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ដុល្លារអាមេរិក | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
|---|---|---|---|---|---|
| ចំណូលពីការប្រាក់ | ១៥ | ៥៧០.២២៦ | ២.៣២៤.៨១១ | ៦៥៣.៤៩៨ | ២.៦៤៧.៩៧៤ |
| ថ្លៃសេវា ចំណូលពីកម្រៃជើងសារ និងចំណូលផ្សេងៗ | ១៦ | ២.៦០៨ | ១០.៦៣៣ | ៨.៤១៣ | ៣៤.០៨៩ |
| ចំណូលប្រត្តិបត្តិការ | | ៥៧២.៨៣៤ | ២.៣៣៥.៤៤៤ | ៦៦១.៩១១ | ២.៦៨២.០៦៣ |
| បម្រែបម្រួលសុទ្ធនៃសំវិធានធន លើឥណទានអាក្រក់ និងជាប់សង្ស័យ | | (៣២៤.១០៩) | (១.៣២១.៣៩២) | (៨០.៣៩៣) | (៣២៥.៧៥២) |
| **ចំណូលការប្រាក់សុទ្ធបន្ទាប់ពីសំវិធានធន លើឥណទានអាក្រក់ និងជាប់សង្ស័យ** | | **២៤៨.៧២៥** | **១.០១៤.០៥២** | **៥៨១.៥១៨** | **២.៣៥៦.៣១១** |
| | | | | | |
| ចំណាយបុគ្គលិក | ១៧ | (៨១.៦៤៤) | (៣៣២.៨៦៣) | (៣១.១៣៨) | (១២៦.១៧១) |
| ចំណាយរំលស់ | ១៨ | (១៤.៤៥៣) | (៥៨.៩២៥) | (២៨.៤៥៦) | (១១៥.៣០៤) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ១៩ | (៦២០.៦៩៣) | (២.៥៣០.៥៦៥) | (៣៣៥.៩៥៣) | (១.៣៦១.២៨២) |
| **(ខាត)/ចំណេញ មុនបង់ពន្ធ** | | **(៤៦៨.០៦៥)** | **(១.៩០៨.៣០១)** | **១៨៥.៩៧១** | **៧៥៣.៥៥៤** |
| ពន្ធលើប្រាក់ចំណូល | ១២(គ) | ២៨.៩០២ | ១១៧.៨៣៣ | (៨៦.៦២៤) | (៣៥១.០០០) |
| **(ខាត)/ចំណេញ សុទ្ធក្នុងការិយបរិច្ឆេទ** | | **(៤៣៩.១៦៣)** | **(១.៧៩០.៤៦៨)** | **៩៩.៣៤៧** | **៤០២.៥៥៤** |
| | | | | | |
| ចំណូលពេញលេញផ្សេងៗ | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (១៥៧.៦៦៦) | - | ២.២៨៥ |
| **សរុប(ខាត)/ចំណេញ ពេញលេញសម្រាប់ការិយបរិច្ឆេទ** | | **(៤៣៩.១៦៣)** | **(១.៩៤៨.១៣៤)** | **៩៩.៣៤៧** | **៤០៤.៨៣៩** |

# របាយការណ៍បម្រែបម្រួលមូលធន

| | ដើមទុន | | ខាតបង្គរ | | លម្អៀងនៃការប្តូររូបិយប័ណ្ណ | មូលធនសរុប | |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| សមតុល្យ ថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ៧.០០០.០០០ | ២៨.១២៦.០០០ | (១.២៧៦.០៦០) | (៥.១២៣.៨៣១) | ៣២២.៨៨៦ | ៥.៧២៣.៩៤០ | ២៣.៣២៥.០៥៥ |
| ប្រាក់ខាតសុទ្ធក្នុងការិយបរិច្ឆេទ | - | - | (៤៣៩.១៦៣) | (១.៧៩០.៤៦៨) | - | (៤៣៩.១៦៣) | (១.៧៩០.៤៦៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | (១៥៧.៦៦៦) | - | (១៥៧.៦៦៦) |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | **៧.០០០.០០០** | **២៨.១២៦.០០០** | **(១.៧១៥.២២៣)** | **(៦.៩១៤.២៩៩)** | **១៦៥.២២០** | **៥.២៨៤.៧៧៧** | **២១.៣៧៦.៩២១** |
| សមតុល្យ ថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ | ៧.០០០.០០០ | ២៨.១២៦.០០០ | (១.៣៧៥.៤០៧) | (៥.៥២៦.៣៨៥) | ៣២០.៦០១ | ៥.៦២៤.៥៩៣ | ២២.៩២០.២១៦ |
| ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | | - | ៩៩.៣៤៧ | ៤០២.៥៥៤ | - | ៩៩.៣៤៧ | ៤០២.៥៥៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | ២.២៨៥ | - | ២.២៨៥ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | **៧.០០០.០០០** | **២៨.១២៦.០០០** | **(១.២៧៦.០៦០)** | **(៥.១២៣.៨៣១)** | **៣២២.៨៨៦** | **៥.៧២៣.៩៤០** | **២៣.៣២៥.០៥៥** |





# របាយការណ៍លំហូរសាច់ប្រាក់

| | កំណត់សម្គាល់ | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| សាច់ប្រាក់សកម្មភាពប្រតិបត្តិការ | | | | | |
| (ខាត)/ចំណេញមុនបង់ពន្ធ | | (៤៦៨.០៦៥) | (១.៩០៨.៣០១) | ១៨៥.៩៧១ | ៧៥៣.៥៥៤ |
| និយ័តកម្ម៖(ខាត)/ចំណេញ | | | | | |
| រំលស់លើទ្រព្យសកម្ម និងទ្រព្យអរូបី | ១៨ | ១៤.៤៥៣ | ៥៨.៩២៥ | ២៨.៤៥៦ | ១១៥.៣០៤ |
| ការលុបចោលឥណទាន និងឥណទេយ្យចេញពីបញ្ជី | | ៤០៥.៨១៦ | ១.៦៥៤.៥១២ | ១.០៣៩ | ៤.២១០ |
| សំវិធានធនលើឥណទានអាក្រក់និង ឥណទានជាប់សង្ស័យ | | ៣២៤.១០៩ | ១.៣២១.៣៩២ | ៨០.៣៩៣ | ៣២៥.៧៥២ |
| **ប្រតិបត្តិការចំណេញ មុនបម្រែបម្រួលទុនបង្វិល** | | **២៧៦.៣១៣** | **១.១២៦.៥២៨** | **២៩៥.៨៥៩** | **១.១៩៨.៨២០** |
| បម្រែបម្រួលទុនបង្វិល សុទ្ធ៖ | | | | | |
| បម្រែបម្រួលក្នុង៖ | | | | | |
| ឥណទានឱ្យអតិថិជន | | ៦៣៥.៧៩៨ | ២.៥៩២.១៤៨ | (៣.៤៨៣.៨៦៤) | (១៤.១១៦.៦១៦) |
| ទ្រព្យសកម្មផ្សេងៗ | | (៧៣.៣៩៨) | (២៩៩.២៤៤) | (៦១២.១២៨) | (២.៤៨០.៣៤៣) |
| បំណុលផ្សេងទៀត | | ៣៦២.០៣៩ | ១.៤៧៦.០៣៣ | ៣១៩.៧៧៨ | ១.២៩៥.៧៤០ |
| **សាច់ប្រាក់សុទ្ធបានពី/(ប្រើប្រាស់ក្នុង) ប្រតិបត្តិការ** | | **១.២០០.៧៥២** | **៤.៨៩៥.៤៦៥** | **(៣.៤៨០.៣៥៥)** | **(១៤.១០២.៣៩៩)** |
| ពន្ធលើប្រាក់ចំណូលបានបង់រួច | ១២(ខ) | (៨០.១៤៣) | (៣២៦.៧៤៣) | (៧.៦០៩) | (៣០.៨៣២) |
| **សាច់ប្រាក់សុទ្ធបានពី/(ប្រើប្រាស់ក្នុង)សកម្មភាពប្រតិបត្តិការ** | | **១.១២០.៦០៩** | **៤.៥៦៨.៧២២** | **(៣.៤៨៧.៩៦៤)** | **(១៤.១៣៣.២៣១)** |
| បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ | | ១.១២០.៦០៩ | ៤.៥៦៨.៧២២ | (៣.៤៨៧.៩៦៤) | (១៤.១៣៣.២៣១) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ | | ៥១៥.២៨៥ | ២.០៩៩.៧៨៧ | ៤.០០៣.២៤៩ | ១៦.០៨៥.០៥៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៥១.៣១៨) | - | ១៤៧.៩៦៣ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ** | **២០** | **១.៦៣៥.៨៩៤** | **៦.៦១៧.១៩១** | **៥១៥.២៨៥** | **២.០៩៩.៧៨៧** |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

## ១ ព័ត៌មានអំពីក្រុមហ៊ុន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ្សូរ៉ ហ្វាយនែនឧប ភីអិលស៊ី ("ក្រុមហ៊ុន") គឺជាស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើង និងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនបានបង្កើតឡើង និងចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ជាមួយក្រសួងពាណិជ្ជកម្មក្រោមអាជ្ញាបណ្ណលេខ Co.០៦៥៣KH/២០១៣ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៣។ ក្រុមហ៊ុន បានទទួលអាជ្ញាប័ណ្ណជាស្ថាប័នមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៣។ នាថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ ក្រុមហ៊ុន បានទទួលលេខចុះបញ្ជីពាណិជ្ជកម្មថ្មីលេខ០០០១៥៦៧៧ ពីក្រសួងពាណិជ្ជកម្ម។

ការិយាល័យកណ្តាលរបស់ក្រុមហ៊ុនស្ថិតនៅ ផ្ទះលេខ១៤៧ មហាវិថីព្រះមុនីវង់ សង្កាត់បឹងសាឡាង ខណ្ឌទួលគោករាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនមានបុគ្គលិកចំនួន ១១នាក់ នាកាលបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩: ៦នាក់) ។

## ២ របាយការណ៍អនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ព្រមទាំងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ត្រូវបានអនុម័តសម្រាប់ចេញផ្សាយ ដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាសលេខ ០៦៨ ប្រ.ក ចុះនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ និងក្រុមប្រឹក្សាគណនេយ្យជាតិ("NAC") ក្រោមប្រកាសលេខ ០៩៧/០៩ ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩។ របាយការណ៍ហិរញ្ញវត្ថុត្រូវបង្ហាញជារូបិយប័ណ្ណដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោលរបស់ក្រុមហ៊ុន។

## ៣ សេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ

### ៣.១ ការពិចារណាជាទូទៅ និងការអនុម័តជាលើកដំបូងនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម

គោលការណ៍គណនេយ្យសំខាន់ៗ ដែលត្រូវបានប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះត្រូវបានសង្ខេបដូចខាងក្រោម។ គោលការណ៍គណនេយ្យទាំងនេះត្រូវបានប្រើប្រាស់គ្រប់ការិយបរិច្ឆេទ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### ៣.២ រូបិយប័ណ្ណគោល និងរូបិយប័ណ្ណបង្ហាញ

រូបិយវត្ថុជាតិរបស់កម្ពុជាគឺជាខ្មែររៀល("KHR")។ ក៏ប៉ុន្តែប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន និងកំណត់ត្រាបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវគិតជាដុល្លារអាមេរិក គណៈគ្រប់គ្រងបានសម្រេចប្រើប្រាស់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណគោលរបស់ក្រុមហ៊ុនសម្រាប់គោលបំណងវាស់វែង និងបង្ហាញដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពសេដ្ឋកិច្ច និងស្ថានការណ៍របស់ក្រុមហ៊ុន។

ប្រតិបត្តិការជារូបិយប័ណ្ណបរទេស ក្រៅពីរូបិយប័ណ្ណដុល្លារអាមេរិក គឺត្រូវបានប្តូរទៅជារូបិយប័ណ្ណដុល្លារអាមេរិក ទៅតាមអត្រាប្តូរប្រាក់ នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ទ្រព្យសកម្មនិងបំណុលផ្សេងៗ ដែលគិតជារូបិយប័ណ្ណក្រៅពីរូបិយប័ណ្ណដុល្លារអាមេរិក នៅកាលបរិច្ឆេទនៃរបាយការណ៍ ត្រូវបានប្តូរទៅជាដុល្លារអាមេរិក ទៅតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលពេញលេញ។





សមតុល្យជាប្រាក់ដុល្លារអាមេរិក អមដោយសមតុល្យជាខ្មែររៀល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញ ដោយអនុលោមតាមច្បាប់ស្តីពីគនេយ្យ និងសវនកម្ម ចេញនៅខែមេសា ឆ្នាំ២០១៦ ព្រមទាំងត្រូវបានធ្វើឡើង ដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការដែលបានបង្ហាញជាប្រាក់រៀលដោយយោងទៅតាមអត្រាប្តូរប្រាក់ក្នុង ១ដុល្លារអាមេរិកដូចដែលបានប្រកាសចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា (២០១៩៖ អគ្គនាយកដ្ឋានពន្ធដារ) ដូចខាងក្រោម៖

| | ២០២០ | ២០១៩ |
|---|---|---|
| អត្រាមធ្យម* | ៤.០៧៧ | ៤.០៥២ |
| អត្រាបិទ | ៤.០៤៥ | ៤.០៧៥ |

*អត្រាមធ្យមត្រូវបានកំណត់ដោយប្រើប្រាស់អត្រាប្តូរប្រាក់ប្រចាំថ្ងៃ ដែលបានប្រកាសចេញផ្សាយដោយធនាគារជាតិនៃកម្ពុជាក្នុងអំឡុងការិយបរិច្ឆេទ។

អត្រាប្តូរប្រាក់ទាំងនេះ មិនត្រូវបានធ្វើសវនកម្ម និងមិនមែនជាមូលដ្ឋានសម្រាប់ការបកស្រាយថាចំនួនទឹកប្រាក់ជាប្រាក់ដុល្លារអាមេរិក នឹងអាចប្តូរទៅជាប្រាក់រៀលនៅថ្ងៃអនាគត ក្រោមអត្រាប្តូរប្រាក់ដដែល ឬអត្រាប្តូរប្រាក់ផ្សេងទៀតឡើយ។

### ៣.៣ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសមតុល្យសាច់ប្រាក់ក្នុងដៃ សមតុល្យសាច់ប្រាក់នៅធនាគារ និងប្រាក់បញ្ញើចរន្តនៅធនាគារ និងការវិនិយោគដែលមានកាលវសានរយៈពេល ៣ខែ ឬតិចជាង ហើយអាចបង្វិលជាសាច់ប្រាក់ភ្លាមៗ ដោយមានហានិភ័យទាបចំពោះការផ្លាស់ប្តូរតម្លៃ។ វាក៏បានរួមបញ្ចូលនូវឥណទានវិបារូបន៍ ដែលការសងត្រលប់មកវិញតាមតម្រូវការ និងជាផ្នែកមួយនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន។

### ៣.៤ ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា

ប្រាក់តម្កល់ធានាដើមទុន ត្រូវបានកំណត់តាមថ្លៃដើម និងតំណាងអោយប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងជាសាច់ប្រាក់ដែលតម្កល់ទុកនៅធនាគារជាតិនៃកម្ពុជា ដែលអនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃកម្ពុជា និងមិនមែនសម្រាប់ធ្វើប្រតិបត្តិការហិរញ្ញប្បទានប្រចាំថ្ងៃរបស់ក្រុមហ៊ុន។ ដូចនេះប្រាក់បញ្ញើនេះ មិនត្រូវបានចាត់ទុកជាផ្នែកមួយនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូលសម្រាប់គោលបំណងនៃរបាយការណ៍លំហូរសាច់ប្រាក់នោះទេ។

### ៣.៥ ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា ត្រូវបានកត់ត្រាតាមតម្លៃដើម។

### ៣.៦ ឥណទានផ្តល់ទៅអតិថិជន

ឥណទានផ្តល់ទៅឱ្យអតិថិជនត្រូវបានទទួលស្គាល់ដំបូងនៅតម្លៃសមស្របណាមួយដែលរាប់បញ្ចូលដោយផ្ទាល់នូវចំណាយប្រតិបត្តិការ និងត្រូវបានវាស់វែងជាបន្តបន្ទាប់តាមវិធីសាស្ត្ររំលស់ថ្លៃដើមដោយប្រើប្រាស់អត្រាការប្រាក់ប្រសិទ្ធភាពដកឱនភាពនៃសំវិធានធន។

ឥណទានត្រូវបានលុបចេញពីបញ្ជីទៅក្នុងរបាយការណ៍ចំណូលពេញលេញ នៅពេលដែលឥណទានត្រូវបានធ្វើសំវិធានធននៅក្នុងតម្លៃពេញ និងតម្លៃនៅសល់ដែលមិនទាន់បានបង់ បន្ទាប់ពីថ្ងៃដល់កាលកំណត់សង ឬនៅពេលដែលមានភាពពិតប្រាកដនៃការមិនអាចប្រមូលឥណទានត្រលប់មកវិញបានបង្ហាញ។ ឥណទានដែលបានលុបចោលត្រូវដកចេញពីសំពៀតឥណទាននៅសល់ និងកាត់ចេញពីសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ។

ការប្រមូលបានមកវិញនូវឥណទានដែលបានលុបចេញពីបញ្ជីពីមុន ត្រូវបានបង្ហាញជាប្រាក់ចំណូលប្រតិបត្តិការផ្សេងៗនៅក្នុងរបាយការណ៍ចំណូលពេញលេញ។ ការកត់បញ្ច្រាស់មកវិញនៃសំវិធានធនពីមុនៗត្រូវបានបង្ហាញនៅក្នុងចំណាយសំវិធានធននៅក្នុងរបាយការណ៍ចំណូលពេញលេញ។

បទប្បញ្ញត្តិសំវិធានធន

ការធ្វើចំណាត់ថ្នាក់ឥណទាន និងការធ្វើសំវិធានធន សម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុដោយអនុលោមតាមប្រកាសលេខ ធ៧-០១៧-៣៨៤ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ ដែលចេញដោយធនាគារជាតិនៃកម្ពុជា ផ្តល់ការណែនាំអំពីការធ្វើចំណាត់ថ្នាក់ឥណទាន និងការធ្វើសំវិធានធនតាមបទប្បញ្ញត្តិសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជា ដែលបានសង្ខេបដូចខាងក្រោម៖

| **ចំណាត់ថ្នាក់** | **ចំនួនថ្ងៃហួសកាលកំណត់សង** | **សំវិធានធន** |
|---|---|---|
| **ឥណទានរយៈពេលវែង (ច្រើនជាងមួយឆ្នាំ)** | | |
| ឥណទានធម្មតា/ស្តង់ដារ | ០ - ២៩ ថ្ងៃ | ១% |
| ឥណទានឃ្លាំមើល | ៣០ - ៨៩ថ្ងៃ | ៣% |
| ឥណទានក្រោមស្តង់ដារ | ៩០ - ១៧៩ថ្ងៃ | ២០% |
| ឥណទានជាប់សង្ស័យ | ១៨០ - ៣៥៩ថ្ងៃ | ៥០% |
| ឥណទានបាត់បង់ | ច្រើនជាង ៣៥៩ថ្ងៃ | ១០០% |
| **ឥណទានរយៈពេលខ្លី(តិចជាងមួយឆ្នាំ)** | | |
| ឥណទានធម្មតា/ស្តង់ដារ | ០ - ១៤ ថ្ងៃ | ១% |
| ឥណទានឃ្លាំមើល | ១៥ - ៣០ថ្ងៃ | ៣% |
| ឥណទានក្រោមស្តង់ដារ | ៣១ - ៦០ថ្ងៃ | ២០% |
| ឥណទានជាប់សង្ស័យ | ៦១ - ៩០ថ្ងៃ | ៥០% |
| ឥណទានបាត់បង់ | ច្រើនជាង ៩០ថ្ងៃ | ១០០% |

មាត្រា ៧៣ នៃប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធន តម្រូវឱ្យធនាគារធ្វើការប្រៀបធៀបសំវិធានធនដែលត្រូវបានគណនាស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពខ្នាតតូច និងមធ្យម និងប្រកាសលេខ ធ៧-០១៧-៣៨៤ ហើយកំណត់ថា៖

១.ក្នុងករណីកម្រិតសំវិធានធនដែលគណនាតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាស ទាបជាង កម្រិតសំវិធានធនដែលបានគណនាស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពខ្នាតតូច និងមធ្យម ក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធនដែលបានគណនាដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពខ្នាតតូច និងមធ្យម។

២.ក្នុងករណីកម្រិតសំវិធានធនដែលគណនាតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងប្រកាស ខ្ពស់ជាងកម្រិតសំវិធានធនដែលគណនាស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពខ្នាតតូច និងមធ្យម ក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធានដែលបានគណនា ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពខ្នាតតូច និងមធ្យម ហើយផ្ទេរភាពខុសគ្នានេះពីគណនីប្រាក់ចំណេញរក្សាទុក ឬខាតបង្គរ ទៅក្នុងគណនីទុនបម្រុងតាមបទបទប្បញ្ញត្តិ ក្នុងខ្នង់មូលនិធិភាគទុនិក នៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។



របាយការណ៍ ប្រចាំឆ្នាំ២០២០

## ៣.៧ ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាតាមតម្លៃដើម។ ការប៉ាន់ស្មានត្រូវបានធ្វើឡើង សម្រាប់គណនីត្រូវទទួលដែលជាប់សង្ស័យ ដោយផ្អែកតាមការត្រួតពិនិត្យចំនួនដែលនៅសល់នាកាលបរិច្ឆេទនៃរបាយការណ៍។

## ៣.៨ ភតិសន្យា

ភតិសន្យា ត្រូវបានចាត់ថ្នាក់ជាភតិសន្យាហិរញ្ញប្បទាន នៅពេលដែលមានការផ្ទេរសិទ្ធនៃទ្រព្យសកម្មក្រោយភតិសន្យាទៅ ឱ្យទៅអ្នកជួល។ ផ្អែកលើការទទួលស្គាល់ដំបូង ទ្រព្យសកម្មដែលបានជួលត្រូវបានវាស់វែងដោយគិតតម្លៃស្មើនឹង តម្លៃសមស្រប ឬតំលៃទីផ្សារដែលទាបជាងថ្លៃឈ្នួលអប្បបរមានៃភតិសន្យា។ បន្ទាប់ពីការទទួលស្គាល់ដំបូង ទ្រព្យសកម្មត្រូវទទួលស្គាល់ផ្អែកតាមគោលនយោបាយគណនេយ្យពាក់ព័ន្ធនឹងទ្រព្យសកម្មនោះ។

ភតិសន្យាផ្សេងទៀត ត្រូវបានចាត់ទុកជាភតិសន្យាប្រតិបត្តិការ។ ភតិសន្យាប្រតិបត្តិការត្រូវបានទទួលស្គាល់ជាចំណាយតាមវិធីសាស្ត្រថេរក្នុងអំឡុងពេលនៃភតិសន្យា។

## ៣.៩ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ បានកត់ត្រាតាមតម្លៃដើម ដករំលស់បង្គរ និងការបង្គរលើការខាតបង់នៃឱនភាព ប្រសិនបើមាន។ ថ្លៃដើមនៃទ្រព្យរួមទាំងចំណាយផ្ទាល់ដែលបានកើតឡើងពេលទិញទ្រព្យសកម្ម។ នៅពេលដែលសមាសធាតុសំខាន់ៗនៃទ្រព្យសម្បត្តិ និងបរិក្ខារមានអាយុកាលប្រើប្រាស់ខុសៗគ្នា ទ្រព្យទាំងនោះត្រូវធ្វើការកត់ត្រាដាច់ដោយឡែកពីគ្នា ទៅតាមប្រភេទនៃទ្រព្យសម្បត្តិ និងបរិក្ខារ។

រំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានទទួលស្គាល់ជាចំណាយក្នុងរបាយការណ៍លទ្ធផលដោយផ្អែកលើមូលដ្ឋានរំលស់ថេរតាមអាយុកាលប្រើប្រាស់របស់ទ្រព្យសម្បត្តិ និងបរិក្ខារនីមួយៗ ដូចខាងក្រោម ៖

| | **អាយុកាលប្រើប្រាស់ប៉ាន់ស្មាន** |
|---|---|
| **ការជួសជុលកែលំអរ** | **តិចជាងរយៈពេលនៃកិច្ចសន្យាជួល ឬ ៥ឆ្នាំ** |
| គ្រឿងសង្ហារឹម និងសម្ភារៈការិយាល័យ | ៤ឆ្នាំ |
| បរិក្ខារព័ត៌មានវិទ្យា និងកុំព្យូទ័រ | ២ឆ្នាំ |
| យានយន្ត | ៤ឆ្នាំ |

វិធីសាស្ត្ររំលស់ អាយុកាល និងតម្លៃកាកសំណល់ ត្រូវបានវាយតម្លៃនៅក្នុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ និងធ្វើនិយ័តកម្មតាមការសមស្រប។

ការចំណាយបន្តបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យសម្បត្តិ និងបរិក្ខារដែលបានទទួលស្គាល់រួចមកហើយត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យនោះ នៅពេលដែលទ្រព្យនោះអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុនលើសពីទ្រព្យដែលមានស្រាប់។ រាល់ការចំណាយបន្តបន្ទាប់ផ្សេងទៀត ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

ចំណេញ ឬខាតពីការឈប់ប្រើ ឬការលក់ចេញទ្រព្យសម្បត្តិ និងបរិក្ខារណាមួយត្រូវបានកំណត់ដោយប្រៀបធៀបរវាងប្រាក់ដែលបានពីការលក់ និងតម្លៃយោងនៃទ្រព្យនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលពេញលេញ នៅពេលដែលទ្រព្យសកម្មនោះ ឈប់ប្រើប្រាស់ ឬបានលក់ចេញ។

ទ្រព្យសម្បត្តិ និងបរិក្ខារដែលបានដករំលស់អស់ហើយត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ថ្ងៃដែលទ្រព្យសម្បត្តិ និងបរិក្ខារ ទាំងនោះត្រូវបានលក់ចេញ ឬលុបបំបាត់ចោល។

## ៣.១០ ទ្រព្យសកម្មអរូបិយ

ទ្រព្យសកម្មអរូបិយ ដែលរួមមានកម្មវិធីកុំព្យូទ័រដែលត្រូវបានកំណត់ដោយតម្លៃដើមដករំលស់បង្គរ និងការបង្គរលើការខាតបង់នៃឱនភាពប្រសិនបើមាន។ ការទិញកម្មវិធី កុំព្យូទ័រត្រូវបានធ្វើមូលធនកម្ម តាមមូលដ្ឋានថ្លៃដើម ដើម្បីទទួលបានកម្មវិធីនោះមកប្រើប្រាស់។ ទ្រព្យសកម្មអរូបិយត្រូវធ្វើរំលស់ដោយគណនាផ្អែកលើមូលដ្ឋានរំលស់ ថេរតាមអត្រា ២០% ក្នុងមួយឆ្នាំ។ ប្រសិនបើមានការចង្អុលបង្ហាញថា មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់លើអត្រារំលស់ លើអាយុកាលប្រើប្រាស់ ឬតម្លៃនៅសល់របស់ ទ្រព្យសកម្មអរូបិយ នោះរំលស់ទ្រព្យសកម្មអរូបិយត្រូវកំណត់ឡើងវិញនិង កែតម្រូវតាមការរំពឹងទុកថ្មី។

## ៣.១១ ឱនភាពទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មដែលធ្វើរំលស់ ត្រូវបានកំណត់ឡើងវិញនៅកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាបញ្ជាក់ថាទ្រព្យសកម្មនោះអាចមានឱនភាពតម្លៃឬទេ។ ប្រសិនបើមានការបង្ហាញណាមួយ ដែលបង្ហាញថាទ្រព្យសកម្មនោះអាចមានឱនភាពនោះតម្លៃយោងរបស់ទ្រព្យសម្បត្តិ (ឬឯកតាបង្កើតសាច់ប្រាក់ហៅកាត់ថា("CGU") ដែលទ្រព្យសកម្មនោះត្រូវបានបែងចែក) ត្រូវបានត្រួតពិនិត្យឱនភាពតម្លៃ។ ការខាតបង់លើឱនភាពតម្លៃនឹងត្រូវបានទទួលស្គាល់ ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម ធំជាងតម្លៃដែលអាចស្រង់មកវិញបាន។

តម្លៃដែលអាចស្រង់មកវិញបាន គឺភាពធំជាងនៃតម្លៃទីផ្សារដកតម្លៃដែលត្រូវលក់ និងតម្លៃដែលត្រូវប្រើប្រាស់របស់ ទ្រព្យសកម្ម (ឬ "CGU") ។ សម្រាប់គោលបំណងនៃការវាយតម្លៃឱនភាព ទ្រព្យសកម្មត្រូវបានបែងចែកជាក្រុមតូចៗបំផុត ដើម្បីកំណត់ពីលំហូរសាច់ប្រាក់របស់វានីមួយៗ (ឯកតាបង្កើតសាច់ប្រាក់)។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុក្រៅពីមូលនិធិពាណិជ្ជកម្ម ដែលមានឱនភាពត្រូវបានត្រួតពិនិត្យសម្រាប់ការកត់បញ្ច្រាស់នៃឱនភាពនៅកាលបរិច្ឆេទរបាយការណ៍នីមួយៗ។

## ៣.១២ កាតព្វកិច្ចចំពោះអត្ថប្រយោជន៍បុគ្គលិក

### ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

ប្រកាសលេខ ៤៤៣ បានចេញផ្សាយនៅថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១៨ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តម្រូវឱ្យក្រុមហ៊ុនធ្វើការទូទាត់ប្រាក់បំណាច់អតីតភាពការងារទៅឱ្យនិយោជិតដែលមានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។ និយោជិតទាំងអស់ដែលបានបម្រើការងារមុនថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ និងកំពុងបន្តបម្រើការងារឱ្យអង្គភាពនឹងទទួលបានការទូទាត់ប្រាក់បំណាច់អតីតភាពការងារដែលស្មើនឹងប្រាក់ឈ្នួលចំនួន ១៥ថ្ងៃ នៅក្នុង ១ឆ្នាំ តែការបើករំលឹកនេះមិនអាចលើសពី ៦ខែ នៃប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមតាមឆ្នាំនីមួយៗទេ ហើយការទូទាត់ប្រាក់បំណាច់អតីតភាពការងារត្រូវបង់រៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៩ ដូចតទៅ៖





- ចំនួន៧.៥ ថ្ងៃ នៅក្នុងខែមិថុនា នៃឆ្នាំនីមួយៗ និង
- ចំនួន ៧.៥ ថ្ងៃ នៅក្នុងខែធ្នូ នៃឆ្នាំនីមួយៗ។

ប្រាក់រំលឹកអតីតភាពការងារត្រូវបានទទួលស្គាល់ពេញនៅក្នុងឆ្នាំ២០១៨ និងប្រាក់បំណាច់អតីតភាពការងារត្រូវបង់នាពេលអនាគត (ចំនួន ១៥ថ្ងៃ ក្នុងមួយឆ្នាំ) ទៅឱ្យនិយោជិត ត្រូវបានទទួលស្គាល់នៅក្នុងអំឡុងពេលដែលនិយោជិតបម្រើការងារ។

នៅថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញនូវសារាចរណែនាំលេខ ០៤២/១៩ ស្តីពីការបើករំលឹកប្រាក់បំណាច់អតីតភាពការងារមុនឆ្នាំ២០១៩ សម្រាប់សហគ្រាស គ្រឹះស្ថាន ក្រៅពីផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងត្រូវបានពន្យារពេលចំពោះការបើកប្រាក់រំលឹកអតីតភាពការងាររហូតដល់ខែធ្នូ ឆ្នាំ២០២១ និងផ្លាស់ប្តូរពីការទូទាត់រំលឹកចំនួន ១៥ ថ្ងៃ នៃប្រាក់ឈ្នួលមធ្យមរៀងរាល់ឆ្នាំនៃរយៈពេលបម្រើការងាររបស់និយោជិត ទៅជាការទូទាត់រំលឹកចំនួន ៦ ថ្ងៃ ដូចតទៅ៖

- ចំនួន៣ ថ្ងៃ នៅក្នុងខែមិថុនា និង
- ចំនួន៣ ថ្ងៃ នៅក្នុងខែធ្នូ នៃឆ្នាំនីមួយៗ។

ចំពោះនិយោជិតដែលមានកិច្ចសន្យាការងារមានថិរវេលាកំណត់ ពួកគេត្រូវទទួលបានប្រាក់បំណាច់បញ្ចប់កិច្ចសន្យានេះយ៉ាងតិចត្រូវស្មើនឹង ៥% នៃប្រាក់ឈ្នួលដែលនិយោជិតបានបើកនៅក្នុងរយៈពេលនៃកិច្ចសន្យានោះ។

ចំពោះនិយោជិតដែលបានលាឈប់ពីការងារដោយឯកឯង នឹងមិនត្រូវបានទទួលនូវការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលនៅសល់នោះទេ។

### អត្ថប្រយោជន៍រយៈពេលខ្លីរបស់បុគ្គលិក

ប្រាក់ឈ្នួល ប្រាក់បៀវត្ស ភាគទានរបបសន្តិសុខសង្គម ការឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួល ការឈប់សម្រាកដោយសារជម្ងឺដែលមានប្រាក់ឈ្នួល បុព្វលាភ ប្រាក់បំណាច់អតីតភាពការងារ និងអត្ថប្រយោជន៍មិនមែនជាសាច់ប្រាក់ផ្សេងទៀត ត្រូវបានវាស់វែងលើមូលដ្ឋានដែលមិនធ្វើអប្បហារ ហើយត្រូវទទួលស្គាល់ជាចំណាយនៅពេលដែលនិយោជិតបម្រើការងារទៅដល់ក្រុមហ៊ុន។

ការឈប់សម្រាកដែលទទួលបានការទូទាត់សងត្រូវបានបង្គរទុករយៈពេលខ្លី មានដូចជា ការឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួល ហើយត្រូវបានទទួលស្គាល់ជាចំណាយនៅពេលដែលនិយោជិតដែលបម្រើការងារបានកើនឡើងច្បាប់ឈប់សម្រាករបស់ពួកគេ ដើម្បីទុកទូទាត់សងការឈប់សម្រាកនាពេលអនាគត។ ការឈប់សម្រាកដែលទទួលបានការទូទាត់សងតែមិនត្រូវបានបង្គរទុករយៈពេលខ្លី មានដូចជា ការឈប់សម្រាកដោយសារជម្ងឺ ត្រូវបានទទួលស្គាល់នៅពេលដែលការឈប់សម្រាកបានកើតឡើង។ និយោជិតដែលបានអនុវត្តតាមគោលការណ៍លាឈប់ដោយឯកឯងបានត្រឹមត្រូវគឺ មានសិទ្ធទទួលបានចំនួនថ្ងៃឈប់សម្រាកប្រចាំឆ្នាំដែលមិនបានប្រើប្រាស់។ និយោជិតអាចទទួលបានការទូទាត់សងប្រសិនបើពួកគេមិនបានប្រើប្រាស់ចំនួនថ្ងៃឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួលអស់។

បុព្វលាភត្រូវបានទទួលស្គាល់ជាចំណាយនៅពេលដែលមានអំណោយ ច្បាប់ ឬក៏កាតព្វកិច្ចដែលមានប្រយោជន៍ដែលធ្វើ ឱ្យមានចំណាយ ជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល និងនៅពេលដែលការប៉ាន់ស្មានដែលអាចជឿទុកចិត្តបានអាចកើតឡើងនូវចំនួនទឹកប្រាក់កាតព្វកិច្ច។

## ៣.១៣ មូលធន ខាតបង្គរ និងសាច់ប្រាក់បម្រុង

ដើមទុនត្រូវបានបង្ហាញនៅក្នុងតម្លៃនៃភាគហ៊ុនដែលបានបោះផ្សាយ។

ខាតបង្គរ រួមបញ្ចូលប្រាក់ចំណេញ ឬ(ខាត) នៅក្នុងគ្រា និងក្នុងការិយបរិច្ឆេទមុនៗ។

## ៣.១៤ ប្រតិបត្តិការសម្ព័ន្ធញាតិ

សម្ព័ន្ធញាតិ គឺជារូបវ័ន្តបុគ្គល ឬអង្គភាពដែលទាក់ទងទៅនឹងក្រុមហ៊ុន។ ប្រតិបត្តិការទាក់ទងនឹងសម្ព័ន្ធញាតិ គឺជាការផ្ទេរធនធាន សេវាកម្ម ឬកាតព្វកិច្ចរវាងក្រុមហ៊ុន និងសម្ព័ន្ធញាតិរបស់ខ្លួន ដោយមិនគិតពីតម្លៃដែលត្រូវបានទូលទាត់ពីភាគីសម្ព័ន្ធញាតិ។

(ក) រូបវ័ន្តបុគ្គល ឬសមាជិកគ្រួសារជិតស្និទ្ធជាមួយនឹងរូបវ័ន្តបុគ្គលដែលទាក់ទងនឹងក្រុមហ៊ុន ប្រសិនបុគ្គលនោះ៖

(១) មានសិទ្ធិគ្រប់គ្រង ឬចូលរួមគ្រប់គ្រងនៅក្នុងក្រុមហ៊ុន

(២) មានឥទ្ធិពលខ្លាំងនៅក្នុងក្រុមហ៊ុន ឬ

(៣) គឺជាសមាជិកនៃគណៈគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុនផ្ទាល់ ឬជាសមាជិកនៃគណៈគ្រប់គ្រងរបស់ក្រុមហ៊ុនមេ។

(ខ) អង្គភាព ដែលចាត់ចូលជាសម្ព័ន្ធញាតិរបស់ក្រុមហ៊ុន ប្រសិនបើនិតិបុគ្គលនោះមានលក្ខណៈដូចខាងក្រោម៖

(១) អង្គភាព និងក្រុមហ៊ុន គឺជាសមាជិកនៃសម្ព័ន្ធក្រុមហ៊ុនតែមួយ

(២) អង្គភាពមួយដែលបានចូលរួម ឬមានការបណ្តាក់ទុនរួមគ្នារបស់អង្គភាពផ្សេងៗទៀត

(៣) អង្គភាពទាំងពីរ គឺជាការបណ្តាក់ទុនរួមគ្នានៃភាគីទីបីដូចគ្នា

(៤) អង្គភាពមួយ គឺជាការបណ្តាក់ទុនរួមគ្នានៃភាគីទីបី ហើយអង្គភាពផ្សេងទៀតគឺជាសហការីនៃអង្គភាពទីបី

(៥) អង្គភាពជាផ្នែកមួយនៃផែនការទទួលបានអត្ថប្រយោជន៍ការងារ សម្រាប់អត្ថប្រយោជន៍របស់នយោជិក រួមមានក្រុមហ៊ុនឬអង្គភាពដែលពាក់ព័ន្ធនឹងក្រុមហ៊ុន។

(៦) អង្គភាពត្រូវបានគ្រប់គ្រង ឬគ្រប់គ្រងរួមគ្នាដោយបុគ្គលដែលបានបញ្ជាក់នៅក្នុងផ្នែក (ក) ខាងលើ។

(៧) បុគ្គលដែលបានបញ្ជាក់នៅក្នុងផ្នែក (ក.១) ខាងលើដែលមានឥទ្ធិពលគួរអោយកត់សម្គាល់លើអង្គភាព ឬជាសមាជិកសំខាន់នៃ គណៈគ្រប់គ្រងក្រុមហ៊ុនមេ។

## ៣.១៥ ឧបករណ៍ហិរញ្ញវត្ថុ

### ទ្រព្យសកម្មហិរញ្ញវត្ថុ

ឥណទានទៅអតិថិជន សាច់ប្រាក់ និងសាច់ប្រាក់សមមូល និងទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះត្រូវបានទទួលស្គាល់ដំបូងតាមប្រតិបត្តិការថ្លៃដើម។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងជាបន្តបន្ទាប់ តាមវិធីសាស្រ្តរំលស់ថ្លៃដើម ដោយប្រើប្រាស់ អត្រាការប្រាក់ប្រសិទ្ធភាព ដក ឱនភាពនៃសំវិធានធន។

នៅពេលដែលមានភស្តុតាងបង្ហាញថាតម្លៃយោងដែលត្រូវទទួលបាន មិនអាចប្រមូលបានមកវិញ នោះការខាតបង់ឱនភាពត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។





### បំណុលហិរញ្ញវត្ថុ

បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមមាន បំណុលផ្សេងៗ។ បំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃប្រតិបត្តិការ។ បន្ទាប់ពីការទទួលស្គាល់ដំបូង បំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងតាមវិធីសាស្រ្តរំលស់ថ្លៃដើម ដោយប្រើប្រាស់អត្រាការប្រាក់ប្រសិទ្ធភាព។ បំណុលផ្សេងៗគឺស្ថិតនៅលើលក្ខខណ្ឌឥណទានធម្មតា និងមិនមានការប្រាក់។

## ៣.១៦ ចំណាយប្រតិបត្តិការផ្សេងៗ

ចំណាយប្រតិបត្តិការផ្សេងៗត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលនៅក្នុងឆ្នាំដែលបានកើតឡើង។

## ៣.១៧ សំវិធានធន

សំវិធានធនត្រូវបានកត់ត្រានៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចបច្ចុប្បន្នដោយស្របច្បាប់ ឬកាតព្វកិច្ចប្រយោល ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាតម្រូវ ឱ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ជាមួយចំនួនទឹកប្រាក់ដែលអាចប៉ាន់ស្មានបាន។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន កម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចនោះទាំងមូល។ សំវិធានធនត្រូវបានកត់ត្រា ទោះបីជាកម្រិតលំហូរចេញនៃខ្ទង់ណាមួយនៅក្នុង ចំណាត់ថ្នាក់កាតព្វកិច្ចដូចគ្នានោះ មានចំនួនតូចក៏ដោយ។

សំវិធានធនត្រូវបានវាស់វែងឡើងវិញតាមតម្លៃបច្ចុប្បន្ននៃចំណាយ ដែលរំពឹងថាត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងអំពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃសាច់ប្រាក់គិតតាមពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធន ដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់។

## ៣.១៨ ការទទួលស្គាល់ចំណូល

ចំណូលការប្រាក់ដែលបានពីឥណទាន ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានបង្គរប្រចាំថ្ងៃ។ នៅពេលដែលឥណទានមួយត្រូវបានចាត់ថ្នាក់ ជាឥណទានមិនដំណើរការ ការកត់ត្រាចំណូលពីការប្រាក់ត្រូវបានព្យួរទុក រហូតដល់ពេលដែលក្រុមហ៊ុនបានទទួលសាច់ប្រាក់ជាក់ស្តែង។

ថ្លៃសេវា និងកម្រៃជើងសារពីសេវាកម្មឥណទាន ត្រូវបានទទួលស្គាល់ជាទ្រព្យហិរញ្ញវត្ថុនៅអត្រាការប្រាក់ប្រសិទ្ធភាព ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ ឧទាហរណ៍ ថ្លៃឈ្នួលឥណទាន (ជាមួយ និងចំណាយថ្លៃដើមផ្ទាល់ដែលពាក់ព័ន្ធ) ត្រូវបានពន្យារ និងទទួលស្គាល់ជាការកែតម្រូវអត្រាការប្រាក់ប្រសិទ្ធភាពលើឥណទាននៅពេលដែលឥណទានត្រូវបានគេបញ្ចេញ។

ថ្លៃសេវាដែលមិនពាក់ព័ន្ធនឹងការដាក់ពាក្យស្នើសុំខ្ចី និងការអោយខ្ចីដែលទទួលបាន ត្រូវបានទទួលស្គាល់ជាចំណូល មិនយឺតជាងនៅពេលដែលឥណទានត្រូវបានបញ្ចេញ ឬកិច្ចសន្យាកម្ចីផុតកាលកំណត់។

ថ្លៃសេវាសម្រាប់បន្តការខ្ចី តំណាង ឱ្យការស្រង់ដើមមកវិញនូវថ្លៃដើមនៃការផ្តល់សេវាកម្ម (ឧទាហរណ៍ ការរក្សា និងកិច្ចការរដ្ឋបាលលើកម្ចីដែលមានស្រាប់) ត្រូវបានទទួលស្គាល់ជាចំណូលនៅពេលសេវាកម្មត្រូវបានបំពេញ។

## ៣.១៩ ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធ ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត រួមមានការបូកបញ្ចូលសរុបនៃពន្ធពន្យា និងពន្ធបច្ចុប្បន្នដែលមិនបានទទួលស្គាល់ក្នុងរបាយការណ៍ចំណូលពេញលេញផ្សេងទៀត ឬរបាយការណ៍មូលធន។

ពន្ធប្រាក់ចំណូលលើទ្រព្យសកម្ម និង ឬ បំណុលរួមមានកាតព្វកិច្ច ឬការតម្រូវពីអាជ្ញាធរសារពើពន្ធសម្រាប់ការិយបរិច្ឆេទ បច្ចុប្បន្ន ឬ សម្រាប់ការិយបរិច្ឆេទកន្លងមកដែលក្រុមហ៊ុនមិនបានទូទាត់។ ពន្ធបច្ចុប្បន្ន គឺ ពន្ធលើប្រាក់ចំណូលត្រូវបង់ ដែលខុសពីចំណេញ ឬខាតក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ពន្ធពន្យាលើប្រាក់ចំណូល ត្រូវបានគណនាដោយប្រើវិធីសាស្ត្របំណុលលើភាពខុសគ្នាបណ្តោះអាសន្នរវាងទឹកប្រាក់យោងនៃទ្រព្យសកម្មនិងបំណុលនិង មូលដ្ឋានពន្ធ ដែលត្រូវបានរំពឹងទុកដើម្បីបង្កើន ឬកាត់បន្ថយប្រាក់ចំណេញជាប់ពន្ធនៅពេលអនាគត និងប្រាក់ខាតពន្ធដែលមិនបានប្រើប្រាស់ និងពន្ធឥណទានដែលមិនប្រើ។

ពន្ធពន្យារទ្រព្យសកម្ម និងបំណុល ត្រូវបានគណនាដោយមិនគិតអប្បហារ នៅអត្រាពន្ធដែលរំពឹងទុកថាអាចប្រើប្រាស់ទៅក្នុងរយៈពេលនៃការអាចសម្រេចផ្តល់ឱ្យដែលត្រូវបានអនុម័ត ឬបានអនុម័តយ៉ាងជាក់លាក់នៅកាលបរិច្ឆេទនៃរបាយការណ៍ ពិចារណាទៅលើលទ្ធផលដែលអាចកើតមានទាំងអស់នៃការពិនិត្យឡើងវិញអាជ្ញាធរពន្ធដារ។ តម្លៃយោងនៃពន្ធពន្យារទ្រព្យសកម្មត្រូវបានពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទនៃរបាយការណ៍ និងកែតម្រូវជាចាំបាច់ទៅតាមការវាយតម្លៃនាពេលបច្ចុប្បន្ននៃពន្ធលើប្រាក់ចំណូលត្រូវបង់នៅពេលអនាគត។

## ៤ ការវិនិច្ឆ័យសំខាន់ៗរបស់គណៈគ្រប់គ្រងក្នុងការប្រើប្រាស់គោលការណ៍គណនេយ្យ និងការប៉ាន់ស្មាន មិនច្បាស់លាស់

ក្រុមហ៊ុនបានធ្វើការប៉ាន់ស្មានការសន្មត និងការវិនិច្ឆ័យទាក់ទងនឹងប្រតិបត្តិការនាពេលអនាគតដែលមានភាពមិនស្មើនឹងលទ្ធផលជាក់ស្តែង។ ការប៉ាន់ប្រមាណគណនេយ្យ ការសន្មត និងការវិនិច្ឆ័យដែលអាចបណ្តាលឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការទទួលស្គាល់និងវាស់វែងលើទ្រព្យសម្បត្តិ បំណុល ចំណូល និងចំណាយត្រូវបានសង្ខេបដូចខាងក្រោម៖

## ៤.១ ការប៉ាន់ស្មាន គណនេយ្យសំខាន់ៗ

ការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ក្នុងការអនុវត្តគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន ដែលមានផលប៉ះពាល់ជាសារវន្ត ទៅលើរបាយការណ៍ហិរញ្ញវត្ថុដែលមានដូចជា៖





**អាយុកាលប្រើប្រាស់នៃការរំលស់ទ្រព្យសកម្ម**

គណៈគ្រប់គ្រងធ្វើការត្រួតពិនិត្យឡើងវិញ លើការប៉ាន់ស្មាននៃអាយុកាលប្រើប្រាស់នៃការរំលស់ទ្រព្យសកម្ម នៅរៀងរាល់កាលបរិច្ឆេទរបាយការណ៍ ដោយផ្អែកលើរយៈពេលនៃការប្រើប្រាស់ដែលបានរំពឹងទុក។

**ការចំណាយពន្ធលើប្រាក់ចំណូល**

ក្រុមហ៊ុននឹងទទួលស្គាល់បំណុល សម្រាប់ការរំពឹងទុកចំណាយពន្ធ ផ្អែកលើការប៉ាន់ស្មាន ថាតើពន្ធកំណត់ដោយ គណៈគ្រប់គ្រងតាមការបកស្រាយបច្ចុប្បន្នពីបទប្បញ្ញត្តិពន្ធផ្សេងៗ អាចនឹងមានការប្រែប្រួល។ ការកំណត់ចុងក្រោយនៃចំណាយពន្ធនឹងត្រូវបានធ្វើឡើងដោយអគ្គនាយកដ្ឋានពន្ធដារ។

នៅពេលដែលលទ្ធផលពន្ធចុងក្រោយ ខុសគ្នាពីចំនួនដែលបានទទួលស្គាល់ដំបូងភាពខុសគ្នានោះនឹងមានផលប៉ះពាល់ទៅលើសំវិធានធនពន្ធ នៅក្នុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលការកំណត់បានធ្វើឡើង។

## ៤.២. ការវិនិច្ឆ័យសំខាន់ៗរបស់គណៈគ្រប់គ្រង

ខាងក្រោមគឺជា ការវិនិច្ឆ័យសំខាន់ៗរបស់គណៈគ្រប់គ្រង ក្នុងការអនុវត្តគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនដែលមានឥទ្ធិពលលើរបាយការណ៍ហិរញ្ញវត្ថុ។

**ការទទួលស្គាល់ពន្ធពន្យាទ្រព្យសកម្ម**

វិសាលភាពនៃពន្ធពន្យាទ្រព្យសកម្មអាចត្រូវបានទទួលស្គាល់ដោយផ្អែកលើការប៉ាន់ស្មាននៃប្រូបាប៊ីលីតេដែលប្រាក់ចំណូលជាប់ពន្ធនាពេលអនាគតនឹងអាចប្រើបានហើយភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន និងខាតតាមមូលដ្ឋានពន្ធ អាចយកមកប្រើប្រាស់បាន។ លើសពីនេះទៅទៀត ការវិនិច្ឆ័យសំខាន់ត្រូវបានទាមទារនៅក្នុងការវាយតម្លៃផលប៉ះពាល់នៃដែនកំណត់ផ្អែកច្បាប់ ឬសេដ្ឋកិច្ចណាមួយ ឬភាពមិនច្បាស់លាស់នៅក្នុងប្រព័ន្ធយុត្តាធិការពន្ធផ្សេងៗ។

## ៥ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៣.២) |
| ប្រាក់រៀល | - | - | ១.៥០៧ | ៦.១៤១ |
| ប្រាក់ដុល្លារអាមេរិក | ៧.១៥៧ | ២៨.៩៥០ | ១៣.៦៨៧ | ៥៥.៧៧៥ |
| | **៧.១៥៧** | **២៨.៩៥០** | **១៥.១៩៤** | **៦១.៩១៦** |

## ៦ ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៣.២) |
| គណនីចរន្ត | ៧.៥១៧ | ៣០.៤០៦ | ៦.៥៤៣ | ២៦.៦៦៣ |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់លើដើមទុន | ៣៥០.០០០ | ១.៤១៥.៧៥០ | ៣៥០.០០០ | ១.៤២៦.២៥០ |
| | **៣៥៧.៥១៧** | **១.៤៤៦.១៥៦** | **៣៥៦.៥៤៣** | **១.៤៥២.៩១៣** |

## ប្រាក់តំកល់ធានាលើដើមទុននៅធនាគារជាតិនៃកម្ពុជា

ប្រាក់តម្កល់ធានាលើដើមទុន ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-00-00៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២000 ស្តីពីអាជ្ញាប័ណ្ណនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាមចំនួនកំណត់ ៥% នៃដើមទុនចុះបញ្ជី។ ប្រាក់តម្កល់នេះមិនអាចយកមកប្រើប្រាស់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃទេប៉ុន្តែ នឹងត្រូវបង្វិលឱ្យក្រុមហ៊ុនវិញនៅពេលដែលក្រុមហ៊ុនបញ្ចប់អាជីវកម្មរបស់ខ្លួន។

ប្រាក់តម្កល់ធានាលើដើមទុនរក្សាទុកនៅធនាគារជាតិ នៃកម្ពុជា ទទួលបានការប្រាក់តាមអត្រាពី 0.៣២% ដល់ 0.៣៦% ក្នុងមួយឆ្នាំ (២០១៩: 0.៣២% ដល់ 0.៣៦% ក្នុងមួយឆ្នាំ)។

## ៧ ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា

| របាយការណ៍ ប្រចាំឆ្នាំ២០២០ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| គណនីសន្សំ | ១.៦២១.២២០ | ៦.៥៥៧.៨៣៥ | ៤៩៣.៥៤៨ | ២.០១១.២០៨ |
| | **១.៦២១.២២០** | **៦.៥៥៧.៨៣៥** | **៤៩៣.៥៤៨** | **២.០១១.២០៨** |

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា ត្រូវបានធ្វើការវិភាគដូចខាងក្រោម ៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| **(ក) តាមរូបិយប័ណ្ណ** | | | | |
| ប្រាក់ដុល្លារអាមេរិក | ១.៦២១.២២០ | ៦.៥៥៧.៨៣៥ | ៤៩៣.៥៤៨ | ២.០១១.២០៨ |
| | **១.៦២១.២២០** | **៦.៥៥៧.៨៣៥** | **៤៩៣.៥៤៨** | **២.០១១.២០៨** |

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| **(ខ) តាមកាលកំណត់** | | | | |
| ក្នុងរយៈពេល១ខែ | ១.៦២១.២២០ | ៦.៥៥៧.៨៣៥ | ៤៩៣.៥៤៨ | ២.០១១.២០៨ |
| | **១.៦២១.២២០** | **៦.៥៥៧.៨៣៥** | **៤៩៣.៥៤៨** | **២.០១១.២០៨** |

ក្រុមហ៊ុនទទួលបានការប្រាក់សម្រាប់ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានាតាមអត្រា ១% ក្នុងមួយឆ្នាំ (២០១៩៖ ១%ក្នុងមួយឆ្នាំ)។





## ៨ ឥណទានផ្តល់ដល់អតិថិជន-សុទ្ធ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| ឥណទានដុលផ្តល់ដល់អតិថិជន | ៣.៨៥៥.៦៨៦ | ១៥.៥៩៦.២៥០ | ៤.៩៧៤.៩០៨ | ២០.២៧២.៧៥០ |
| បង្គរការប្រាក់ត្រូវទទួលបាន | ៧៧.៦០៧ | ៣១៣.៩២១ | - | - |
| ឥណទានផ្តល់ដល់អតិថិជន៖ ដុល | ៣.៩៣៣.២៩៣ | ១៥.៩១០.១៧១ | ៤.៩៧៤.៩០៨ | ២០.២៧២.៧៥០ |
| សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យទូទៅ | (៦២៩.២៣៧) | (២.៥៤៥.២៦៤) | (៣០៥.១២៨) | (១.២៤៣.៣៩៧) |
| **ឥណទានផ្តល់ដល់អតិថិជន៖ សុទ្ធ** | **៣.៣០៤.០៥៦** | **១៣.៣៦៤.៩០៧** | **៤.៦៦៩.៧៨០** | **១៩.០២៩.៣៥៣** |

បម្រែបម្រួលនៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យមានដូចខាងក្រោម ៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| សមតុល្យនាដើមការិយបរិច្ឆេទ | ៣០៥.១២៨ | ១.២៤៣.៣៩៧ | ២២៤.៧៣៥ | ៩០២.៩៨៤ |
| សំវិធានធនក្នុងឆ្នាំ | ៣២៤.១០៩ | ១.៣២១.៣៩២ | ៨០.៣៩៣ | ៣២៧.៦០១ |
| លំអៀងនៃការប្តូររូបិយប័ណ្ណ | - | (១៩.៥២៥) | - | ១២.៨១២ |
| **នាថ្ងៃចុងការិយបរិច្ឆេទ** | **៦២៩.២៣៧** | **២.៥៤៥.២៦៤** | **៣០៥.១២៨** | **១.២៤៣.៣៩៧** |

ឥណទានដុលផ្តល់ឱ្យអតិថិជន ត្រូវបានធ្វើការវិភាគដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| **(ក) តាមរូបិយប័ណ្ណ:** | | | | |
| ប្រាក់ដុល្លារអាមេរិក | ៣.៨៧៨.៣៥៨ | ១៥.៦៨៧.៩៥៨ | ៤.៩៧៤.៩០៨ | ២០.២៧២.៧៥០ |
| ខ្មែររៀល | ៥៤.៩៣៥ | ២២២.២១៣ | - | - |
| | **៣.៩៣៣.២៩៣** | **១៥.៩១០.១៧១** | **៤.៩៧៤.៩០៨** | **២០.២៧២.៧៥០** |
| **(ខ) តាមផ្នែកឧស្សាហកម្ម:** | | | | |
| សេវាកម្ម | - | - | ១៤៦.៣៧៣ | ៥៩៦.៤៧០ |
| អាជីវកម្ម និងពាណិជ្ជកម្ម | - | - | ១.០៣៣.៣៤១ | ៤.២១០.៨៦៥ |
| គ្រួសារ | ៣.៩៣៣.២៩៣ | ១៥.៩១០.១៧១ | ៣.៦៧៩.៣៣៦ | ១៤.៩៩៣.២៩៤ |
| ផ្សេងៗ | - | - | ១១៥.៨៥៨ | ៤៧២.១២១ |
| | **៣.៩៣៣.២៩៣** | **១៥.៩១០.១៧១** | **៤.៩៧៤.៩០៨** | **២០.២៧២.៧៥០** |

(គ) តាមនិវាសនដ្ឋាន:

| | | | | |
|---|---|---|---|---|
| និវាសនជន | ៣.០៥៦.២៨០ | ១២.៣៦២.៦៥៤ | ៤.០៤៤.៦៤៨ | ១៦.៤៨១.៩៤០ |
| អនិវាសនជន | ៨៧៧.០១៣ | ៣.៥៤៧.៥១៧ | ៩៣០.២៦០ | ៣.៧៩០.៨១០ |
| | ៣.៩៣៣.២៩៣ | ១៥.៩១០.១៧១ | ៤.៩៧៤.៩០៨ | ២០.២៧២.៧៥០ |

(ឃ) តាមទំនាក់ទំនង:

| | | | | |
|---|---|---|---|---|
| ភាគីឥតពាក់ព័ន្ធ | ៣.៩៣៣.២៩៣ | ១៥.៩១០.១៧១ | ៤.៩៧៤.៩០៨ | ២០.២៧២.៧៥០ |

(ង) តាមចំណាត់ថ្នាក់ឥណទាន:

| | | | | |
|---|---|---|---|---|
| ឥណទានស្តង់ដារមានវត្ថុបញ្ចាំ | ៣.១២៨.២៣០ | ១២.៦៥៣.៦៩១ | ៤.៩០០.៥៤២ | ១៩.៩៦៩.៧០៩ |
| ឥណទានឃ្លាំមើល | ៣២៧.៧៩៧ | ១.៣២៥.៩៣៩ | ៧៤.៣៦៦ | ៣០៣.០៤១ |
| ឥណទានក្រោមស្តង់ដារមានវត្ថុបញ្ចាំ | ១០១.១៩៩ | ៤០៩.៣៥០ | - | - |
| ឥណទានជាប់សង្ស័យមានវត្ថុបញ្ចាំ | ៣៧៦.០៦៧ | ១.៥២១.១៩១ | - | - |
| | ៣.៩៣៣.២៩៣ | ១៥.៩១០.១៧១ | ៤.៩៧៤.៩០៨ | ២០.២៧២.៧៥០ |

ឥណទានដែលមានវត្ថុបញ្ចាំ គឺជាឥណទានដែលមានវត្ថុបញ្ចាំក្រោមរូបភាពជាដី ឬបង្កាន់ដៃដី និងប្លង់ផ្ទះ (ដែលមិនមានប្លង់ដីជាផ្លូវការ) នៅពេលក្រុមហ៊ុនជាទូទៅបានបញ្ចេញឥណទានទៅឱ្យសហគ្រាស នៅតាមខេត្តនានា។

(ច) តាមអត្រាការប្រាក់:

អត្រាការប្រាក់ដែលមាននៅក្នុងប្រតិបត្តិការនាចុងការិយបរិច្ឆេទមានដូចខាងក្រោម ៖

| | ២០២០ | ២០១៩ |
|---|---|---|
| សេវាកម្ម | - | ៥%¬-១៣% |
| អាជីវកម្ម និងពាណិជ្ជកម្ម | - | ១២% |
| គ្រួសារ | ៥%-១៤.៤% | ១២%-១៤.៤% |
| ផ្សេងៗ | - | ១៤% |

៩ ទ្រព្យសកម្មផ្សេងៗ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| ចំនួនទឹកប្រាក់ជំពាក់ពីក្រុមហ៊ុនមេ | ១.១២៨.៨៨៦ | ៤.៥៦៦.៣៤៤ | ៦០០.៨៦៦ | ២.៤៤៨.៥២៩ |
| ចំនួនទឹកប្រាក់ជំពាក់ទៅភាគីសម្ព័ន្ធញាត្តិ | ៣៧.៨៤៥ | ១៥៣.០៨៣ | ៤៩២.៤១៣ | ២.០០៦.៥៨៣ |
| ប្រាក់បញ្ញើ | ១៥.០៩០ | ៦១.០៣៩ | ១៥.៤៤០ | ៦២.៩១៨ |
| ចំណាយបង់មុន | ៥.២៣០ | ២១.១៥៥ | - | - |
| គណនីត្រូវទទួលបាន | ៩០៣ | ៣.៦៥៣ | ៩០៣ | ៣.៦៨០ |
| បង្គរការប្រាក់ត្រូវទទួលបាន | ២២៣ | ៩០២ | - | - |
| | ១.១៨៨.១៧៧ | ៤.៨០៦.១៧៦ | ១.១០៩.៦២២ | ៤.៥២១.៧១០ |





១០ ទ្រព្យសម្បត្តិ និងបរិក្ខារ

| | ការជួសជុលកែលំអរ | គ្រឿងសង្ហារឹមនិងសម្ភារៈការិយាល័យ | បរិក្ខារព័ត៌មានវិទ្យា និងកុំព្យូទ័រ | យានយន្ត | សរុប | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| **តម្លៃយោងដុល** | | | | | | |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២០ | ១៩៦.៦៦៧ | ៦២.៧៤៣ | ៤៣.៨៣៥ | ២៨.០០០ | ៣៣១.២៤៥ | ១.៣៤៩.៨២៣ |
| ការលម្អៀងរូបិយប័ណ្ណ | - | - | - | - | - | (៩.៩៣៧) |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ | ១៩៦.៦៦៧ | ៦២.៧៤៣ | ៤៣.៨៣៥ | ២៨.០០០ | ៣៣១.២៤៥ | ១.៣៣៩.៨៨៦ |
| **រំលស់បង្គរ** | | | | | | |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២០ | ១៩៤.៥២៥ | ៦២.៧១៩ | ៤៣.៨៣៥ | ២៨.០០០ | ៣២៩.០៧៩ | ១.៣៤០.៩៩៧ |
| រំលស់ក្នុងការិយបរិច្ឆេទ | ៧៩១ | ២៤ | - | - | ៨១៥ | ៣.៣២៣ |
| ការលម្អៀងរូបិយប័ណ្ណ | - | - | - | - | - | (៩.៨៩៩) |
| នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០ | ១៩៥.៣១៦ | ៦២.៧៤៣ | ៤៣.៨៣៥ | ២៨.០០០ | ៣២៩.៨៩៤ | ១.៣៣៤.៤២១ |
| **តម្លៃយោងនាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០** | ១.៣៥១ | - | - | - | ១.៣៥១ | ៥.៤៦៥ |
| **តម្លៃយោងដុល** | | | | | | |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៩ | ១៩៦.៦៦៧ | ៦២.៧៤៣ | ៤៣.៨៣៥ | ២៨.០០០ | ៣៣១.២៤៥ | ១.៣៣០.៩៤២ |
| ការលម្អៀងរូបិយប័ណ្ណ | - | - | - | - | - | ១៨.៨៨១ |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ | ១៩៦.៦៦៧ | ៦២.៧៤៣ | ៤៣.៨៣៥ | ២៨.០០០ | ៣៣១.២៤៥ | ១.៣៤៩.៨២៣ |
| **រំលស់** | | | | | | |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៩ | ១៨៥.៩៥១ | ៥៩.៨៤៩ | ៤២.៥០១ | ២៦.៨៤២ | ៣១៥.១៤៣ | ១.២៦៦.២៤៤ |
| រំលស់ក្នុងការិយបរិច្ឆេទ | ៨.៥៧៤ | ២.៨៧០ | ១.៣៣៤ | ១.១៥៨ | ១៣.៩៣៦ | ៥៦.៤៦៩ |
| ការលម្អៀងរូបិយប័ណ្ណ | - | - | - | - | - | ១៨.២៨៤ |
| នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៩ | ១៩៤.៥២៥ | ៦២.៧១៩ | ៤៣.៨៣៥ | ២៨.០០០ | ៣២៩.០៧៩ | ១.៣៤០.៩៩៧ |
| **តម្លៃយោងនាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៩** | ២.១៤២ | ២៤ | - | - | ២.១៦៦ | ៨.៨២៦ |

## ១១ ទ្រព្យសកម្មអរូបិយ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| **តម្លៃយោងដុល** | | | | |
| នាថ្ងៃទី ១ ខែមករា | ៨៤.២៨៩ | ៣៤៣.៤៧៨ | ៨៤.២៨៩ | ៣៣៨.៦៧៣ |
| លំអៀងនៃការប្តូររូបិយប័ណ្ណ | - | (២.៥២៩) | - | ៤.៨០៥ |
| **នាថ្ងៃទី ៣១ ខែធ្នូ** | **៨៤.២៨៩** | **៣៤០.៩៤៩** | **៨៤.២៨៩** | **៣៤៣.៤៧៨** |
| **ដក៖ រំលស់បង្គរ** | | | | |
| នាថ្ងៃទី ១ ខែមករា | ៥៨.០៣៣ | ២៣៦.៤៨៥ | ៤៣.៥១៣ | ១៧៤.៨៣៥ |
| រំលស់ | ១៣.៦៣៨ | ៥៥.៦០២ | ១៤.៥២០ | ៥៨.៨៣៥ |
| លំអៀងនៃការប្តូររូបិយប័ណ្ណ | - | (២.១៧៨) | - | ២.៨១៥ |
| **នាថ្ងៃទី ៣១ ខែធ្នូ** | **៧១.៦៧១** | **២៨៩.៩០៩** | **៥៨.០៣៣** | **២៣៦.៤៨៥** |
| **តម្លៃយោងនាថ្ងៃទី ៣១ ខែធ្នូ** | **១២.៦១៨** | **៥១.០៤០** | **២៦.២៥៦** | **១០៦.៩៩៣** |

## ១២ ពន្ធលើប្រាក់ចំណូល

### (ក) ពន្ធពន្យាទ្រព្យសកម្មសុទ្ធ

ពន្ធពន្យាទ្រព្យសកម្ម រួមមាន៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| សំវិធានធនលើឥណទានបាត់បង់* | ៣៧.០៧៩ | ១៤៩.៩៨៥ | ៤.០៦៦ | ១៦.៥៦៩ |
| រំលស់តាមពន្ធ | ១៨.៨១៤ | ៧៦.១០២ | ២១.៥៦៥ | ៨៧.៨៧៧ |
| **ពន្ធពន្យាលើទ្រព្យសកម្ម៖ សុទ្ធ** | **៥៥.៨៩៣** | **២២៦.០៨៧** | **២៥.៦៣១** | **១០៤.៤៤៦** |

បម្រែបម្រួលនៃពន្ធពន្យាទ្រព្យសកម្មសុទ្ធ មានដូចខាងក្រោម:

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| នាថ្ងៃទី១ ខែមករា | ២៥.៦៣១ | ១០៤.៤៤៦ | ៣២.៤២៦ | ១៣០.២៨៨ |
| បានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផល | ៣០.២៦២ | ១២៣.៣៧៨ | (៦.៧៩៥) | (២៧.៦៩០) |
| លំអៀងនៃការប្តូររូបិយប័ណ្ណ | - | (១.៧៣៧) | - | ១.៨៤៨ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ** | **៥៥.៨៩៣** | **២២៦.០៨៧** | **២៥.៦៣១** | **១០៤.៤៤៦** |





(*) ពន្ធពន្យាទ្រព្យសកម្មនេះ កើតឡើងពីសំវិធានធនទូទៅនឹងជាក់លាក់ ដែលចាត់ថ្នាក់ជាឥណទានក្រោមស្តង់ដារ ដែលជាចំណាយមិនអាចកាត់កងជាបណ្តោះអាសន្ន បានដោយអនុលោមតាមប្រកាសថ្មីលេខ ១៥៣៥ សហវ ប្រ.ក របស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦។

### (ខ) ពន្ធលើប្រាក់ចំណូលត្រូវទូទាត់

| | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| នាថ្ងៃទី១ ខែមករា | ៧៤.៣៩៤ | ៣០៣.១៥៦ | ២.១៧៤ | ៨.៧៣៥ |
| ចំណាយពន្ធលើប្រាក់ចំណូល | - | - | ៧៩.៨២៩ | ៣២៥.៣០៣ |
| ពន្ធលើប្រាក់ចំណេញបានទូទាត់មុន | ៥.១៥៦ | ២០.៨៥៤ | - | - |
| សំវិធានធននៃពន្ធពីឆ្នាំមុន | ១.៣៦០ | ៥.៥៤៥ | - | - |
| ប្រាក់ពន្ធបានបង់ | (៨០.១៤៣) | (៣២៦.៧៤៣) | (៧.៦០៩) | (៣១.០០៧) |
| លំអៀងនៃការប្តូររូបិយប័ណ្ណ | - | ២៩៣ | - | ១២៥ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ** | **៧៦៧** | **៣.១០៥** | **៧៤.៣៩៤** | **៣០៣.១៥៦** |

### (គ) ចំណាយនៃពន្ធលើប្រាក់ចំណូល

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| ពន្ធលើប្រាក់ចំណូល | - | - | ៧៩.៨២៩ | ៣២៣.៤៦៧ |
| សំវិធានធននៃពន្ធពីឆ្នាំមុន | ១.៣៦០ | ៥.៥៤៥ | - | - |
| ពន្ធពន្យា | (៣០.២៦២) | (១២៣.៣៧៨) | ៦.៧៩៥ | ២៧.៥៣៣ |
| | **(២៨.៩០២)** | **(១១៧.៨៣៣)** | **៨៦.៦២៤** | **៣៥១.០០០** |

អនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលដោយគណនាតាមអត្រា ២០%នៃប្រាក់ចំណូលជាប់ពន្ធ ឬពន្ធអប្បបរមាដោយគណនាតាមអត្រា ១%នៃប្រាក់ចំណូលសរុប ដោយយកចំនួនដែលធំជាងគេ។

ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណូល ដែលគណនាតាមអត្រាច្បាប់ពន្ធទៅនឹងការចំណាយលើពន្ធក្នុងការិយបរិច្ឆេទ មានដូចខាងក្រោម ៖

| | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| **(ខាត)/ចំណេញគណនេយ្យ** | **(៤៦៨.០៦៥)** | **(១.៩០៨.៣០១)** | **១៨៥.៩៧១** | **៧៥៣.៥៥៤** |
| **និយ័តកម្ម៖** | | | | |
| ដក៖ ការចំណាយដែលមិនអាចកាត់កងសម្រាប់ពន្ធលើប្រាក់ចំណូល | ១៣៧.៦០៩ | ៥៦១.០៣០ | ២៤៧.១៤៩ | ១.០០១.៤៤៦ |
| ចំណេញជាប់ពន្ធ | (៣៣០.៤៥៦) | (១.៣៤៧.២៧១) | ៤៣៣.១២០ | ១.៧៥៥.០០០ |
| ពន្ធលើប្រាក់ចំណូល (អត្រា ២០%) | - | - | ៨៦.៦២៤ | ៣៥១.០០០ |
| ពន្ធអប្បបរមា (អត្រា១% នៃចំណូល) | - | - | ៦.៦១៩ | ២៦.៨២១ |
| ចំណាយពន្ធលើប្រាក់ចំណូលដែលបានប៉ាន់ប្រមាណ | - | - | ៨៦.៦២៤ | ៣៥១.០០០ |
| បម្រែបម្រួលពន្ធពន្យាទ្រព្យសកម្ម | (៣០.២៦២) | (១២៣.៣៧៨) | - | - |
| សំវិធានធននៃពន្ធពីឆ្នាំមុន | ១.៣៦០ | ៥.៥៤៥ | - | - |
| **ចំណាយពន្ធលើប្រាក់ចំណូលដែលបានប៉ាន់ប្រមាណ** | **(២៨.៩០២)** | **(១១៧.៨៣៣)** | **៨៦.៦២៤** | **៣៥១.០០០** |

ប្រព័ន្ធពន្ធដារនៅព្រះរាជាណាចក្រកម្ពុជាមានសភាពថ្មីហើយពន្ធត្រូវបានបែងចែកជាច្រើនប្រភេទ និងបទប្បញ្ញត្តិមានការផ្លាស់ប្តូរញឹកញាប់ដែលជាធម្មតាពុំមានភាពច្បាស់លាស់ មានភាពផ្ទុយគ្នា និងពឹងផ្អែកនៃការបកស្រាយ។ ជាញឹកញាប់ការបកស្រាយខុសគ្នាជាច្រើនតែងកើតមានឡើងក្នុងចំណោមអាជ្ញាធរពន្ធដារ និងយុត្តាធិការ។ ពន្ធដារ គឺជាកម្មវត្ថុនៃការពិនិត្យឡើងវិញ និងការសង្កេតដោយភ្នាក់ងារពន្ធដារផ្សេងៗជាច្រើន ដែលមានសមត្ថកិច្ចក្នុងការផាកពិន័យធ្ងន់ធ្ងរនិងពិន័យលើការប្រាក់។

កត្តាទាំងនេះហើយដែលអាចធ្វើឱ្យមានហានិភ័យពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជាខ្លាំងជាងប្រទេសដទៃទៀត។ គណៈគ្រប់គ្រងមានការជឿជាក់ថា ខ្លួនបានធ្វើសំវិធានធនបំណុលពន្ធគ្រប់គ្រាន់ដោយផ្អែកលើការបកស្រាយបទប្បញ្ញត្តិពន្ធរបស់ខ្លួន។ ទោះបីយ៉ាងនេះក្តី សមត្ថកិច្ចពាក់ព័ន្ធអាចការបកស្រាយខុសៗគ្នា ហើយអាចធ្វើឱ្យមានផលប៉ះពាល់ជាសារវន្តបាន។

## ១៣ បំណុលផ្សេងៗ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| ចំនួនទឹកប្រាក់ជំពាក់ទៅភាគីសម្ព័ន្ធញាត្តិ | ១.១៤៧.៥៤៥ | ៤.៦៤១.៨២០ | ៧៥៨.០៧២ | ៣.០៨៩.១៤៣ |
| ចំនួនទឹកប្រាក់ជំពាក់ពីក្រុមហ៊ុនមេ | ៧០.៦៣៨ | ២៨៥.៧៣១ | - | - |
| ប្រាក់បញ្ញើអតិថិជន | ២២.២៩៥ | ៩០.១៨៣ | ២.៦០១ | ១០.៥៩៩ |
| ចំណាយបង្គរ | ១៤.២៧២ | ៥៧.៧៣០ | ១៣៧.៤៨៣ | ៥៦០.២៤៣ |
| គណនីត្រូវបង់ | ៧.១៥៩ | ២៨.៩៥៨ | ១.៧៥០ | ៧.១៣១ |
| ពន្ធផ្សេងៗត្រូវទូទាត់ | ៥៣៦ | ២.១៦៨ | ៥០០ | ២.០៣៨ |
| | **១.២៦២.៤៤៥** | **៥.១០៦.៥៩០** | **៩០០.៤០៦** | **៣.៦៦៩.១៥៤** |



របាយការណ៍ ប្រចាំឆ្នាំ២០២០

## ១៤ ដើមទុន

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| ភាគហ៊ុនមានតម្លៃចារឹក២.៥០ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន | | | | |
| ដើមទុនបានបោះផ្សាយចំនួន២.៨០០.០០០ហ៊ុន | ៧.០០០.០០០ | ២៨.១២៦.០០០ | ៧.០០០.០០០ | ២៨.១២៦.០០០ |

## ១៥ ចំណូលពីការប្រាក់

| | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| ការប្រាក់ទទួលបានពី៖ | | | | |
| ឥណទានផ្តល់ដល់អតិថិជន | ៥៦៣.៦៦០ | ២.២៩៨.០៤១ | ៦៤៤.៤៦១ | ២.៦១១.៣៥៦ |
| ប្រាក់តម្កល់នៅធនាគារនានា | ៥.៥៧២ | ២២.៧១៧ | ៦.៨៣៥ | ២៧.៦៩៥ |
| ប្រាក់តម្កល់ដើមទុននៅធនាគារជាតិនៃកម្ពុជា | ៩៩៤ | ៤.០៥៣ | ២.២០២ | ៨.៩២៣ |
| | **៥៧០.២២៦** | **២.៣២៤.៨១១** | **៦៥៣.៤៩៨** | **២.៦៤៧.៩៧៤** |

## ១៦ ថ្លៃឈ្នួល កម្រៃជើងសារ និងចំណូលផ្សេងៗ

| | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| ថ្លៃឈ្នួល និងកម្រៃជើងសារ | ២.២៥៥ | ៩.១៩៤ | ៨.២៩៣ | ៣៣.៦០៣ |
| ផ្សេងៗ | ៣៥៣ | ១.៤៣៩ | ១២០ | ៤៨៦ |
| | **២.៦០៨** | **១០.៦៣៣** | **៨.៤១៣** | **៣៤.០៨៩** |

## ១៧ ចំណាយបុគ្គលិក

| | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| ប្រាក់បៀវត្ស និងប្រាក់ឈ្នួល | ៧៤.៥៤៤ | ៣០៣.៩១៦ | ២៨.២១៩ | ១១៤.៣៤៣ |
| អត្ថប្រយោជន៍ផ្សេងទៀតរបស់បុគ្គលិក | ៧.១០០ | ២៨.៩៤៧ | ២.៩១៩ | ១១.៨២៨ |
| | **៨១.៦៤៤** | **៣៣២.៨៦៣** | **៣១.១៣៨** | **១២៦.១៧១** |

## ១៨ ចំណាយរំលស់

| | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| ចំណាយរំលស់លើទ្រព្យអរូបិយ | ១៣.៦៣៨ | ៥៥.៦០២ | ១៤.៥២០ | ៥៨.៨៣៥ |
| ចំណាយរំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារ | ៨១៥ | ៣.៣២៣ | ១៣.៩៣៦ | ៥៦.៤៦៩ |
| | ១៤.៤៥៣ | ៥៨.៩២៥ | ២៨.៤៥៦ | ១១៥.៣០៤ |

## ១៩ ចំណាយទូទៅ និង រដ្ឋបាល

| | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| ការលុបចោលឥណទាន និងឥណទេយ្យចេញពីបញ្ជី | ៤០៥.៨១៦ | ១.៦៥៤.៥១២ | ១.០៣៩ | ៤.២១០ |
| ចំណាយប្រតិបត្តិការ និងធានា | ៩២.៧៣៤ | ៣៧៨.០៧៧ | ៦២.០៥៨ | ២៥១.៤៥៩ |
| ចំណាយជួលអគារ ចំណាយជួលផ្សេងៗ | ៣៨.២៤៤ | ១៥៥.៩២១ | ៤២.៦៣៣ | ១៧២.៧៤៩ |
| ចំណាយថ្លៃវិជ្ជាជីវៈ | ២២.៥៩៤ | ៩២.១១៦ | ៣១.២៣៦ | ១២៦.៥៦៨ |
| ចំណាយលើការជួសជុលនិងថែទាំ | ១២.៧៤៤ | ៥១.៩៥៧ | ១០.១៨០ | ៤១.២៤៩ |
| ចំណាយទឹកភ្លើង | ៩.៨០៩ | ៣៩.៩៩១ | ៩.០០៥ | ៣៦.៤៨៨ |
| ចំណាយសន្តិសុខ | ៧.៩៨៦ | ៣២.៥៥៩ | ៧.៤១៤ | ៣០.០៤២ |
| ពន្ធ និងអាជ្ញាប័ណ្ណផ្សេងៗ | ៦.៣៣៣ | ២៥.៨២០ | ៧.៦៨៤ | ៣១.១៣៦ |
| ចំណាយទំនាក់ទំនង | ៥.៧៣៣ | ២៣.៣៧៣ | ៤.៦៥៦ | ១៨.៨៦៦ |
| ថ្លៃធ្វើដំណើរ | ៤.៣១៤ | ១៧.៥៨៨ | ៨៤៥ | ៣.៤២៤ |
| ចំណាយប្រឹក្សាយោបល់ | ១.៧០០ | ៦.៩៣១ | ៣៥.៧០០ | ១៤៤.៦៥៦ |
| សម្ភារការិយាល័យ និងការបោះពុម្ព | ៦៧៥ | ២.៧៥២ | ៤.៧៦០ | ១៩.២៨៨ |
| ចំណាយលើពន្ធផ្សេងៗ | ១៤៣ | ៥៨៣ | ៦៨៩ | ២.៧៩២ |
| ថ្លៃសេវាធនាគារ | ១២០ | ៤៨៩ | ២៤២ | ៩៨១ |
| ចំណាយផ្សេងៗ | ១១.៧៤៨ | ៤៧.៨៩៦ | ១៤.៩៨១ | ៦០.៧០៣ |
| ការទូទាត់ | - | - | ១០២.៨៣១ | ៤១៦.៦៧១ |
| | ៦២០.៦៩៣ | ២.៥៣០.៥៦៥ | ៣៣៥.៩៥៣ | ១.៣៦១.២៨២ |





## ២០ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| សាច់ប្រាក់ក្នុងដៃ | ៧.១៥៧ | ២៨.៩៥០ | ១៥.១៩៤ | ៦១.៩១៦ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា៖ គណនីចរន្ត | ៧.៥១៧ | ៣០.៤០៦ | ៦.៥៤៣ | ២៦.៦៦៣ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា៖ គណនីសន្សំ | ១.៦២១.២២០ | ៦.៥៥៧.៨៣៥ | ៤៩៣.៥៤៨ | ២.០១១.២០៨ |
| | ១.៦៣៥.៨៩៤ | ៦.៦១៧.១៩១ | ៥១៥.២៨៥ | ២.០៩៩.៧៨៧ |

## ២១ ប្រតិបត្តិការ និងសមតុល្យជាមួយសម្ព័ន្ធញាតិ

(ក) ប្រតិបត្តិការដែលមានជាមួយភាគីពាក់ព័ន្ធនៅក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|
| **សម្ព័ន្ធញាតិ** | **ទំនាក់ទំនង** | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២ |
| **ម៉ាហា ហ្វេមីលី ប្រជីធី ខូ អិលធីឌី** | **ក្រុមហ៊ុនមេ** | | | | |
| សេវាធានា | | ៧០.៦៣៨ | ២៨៧.៩៩៣ | ៣០.៩៦៣ | ១២៥.៤៦២ |
| **ជីលក្វាំ អ៊ែរសេត ហូលឌីង ខូ អិលធីឌី** | **ក្រុមហ៊ុនបុត្រសម្ព័ន្ធរួម** | | | | |
| សេវាធានា | | ២២.០៩៦ | ៩០.០៨៤ | ១៣១ | ៥៣១ |

(ខ) សមតុល្យដែលនៅសល់ជាមួយភាគីពាក់ព័ន្ធមានដូចខាងក្រោម៖

| | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|
| **សម្ព័ន្ធញាតិ** | **ទំនាក់ទំនង** | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| **ម៉ាហា ហ្វេមីលី ប្រជីធី ខូ អិលធីឌី** | **ក្រុមហ៊ុនមេ** | | | | |
| សមតុល្យជំពាក់ពី | | ១.១២៨.៨៨៦ | ៤.៥៦៦.៣៨៤ | ៦០០.៨៦៦ | ២.៤៤៨.៥២៩ |
| សមតុល្យជំពាក់ទៅ | | ៧០.៦៣៨ | ២៨៥.៧៣១ | - | - |
| **ជីលក្វាំ អ៊ែរសេត ហូលឌីង ខូ អិលធីឌី** | **ក្រុមហ៊ុនបុត្រសម្ព័ន្ធរួម** | | | | |
| សមតុល្យជំពាក់ពី | | - | - | ៤២.៨៤៨ | ១៧៤.៦០៦ |
| សមតុល្យជំពាក់ទៅ | | ១.១៤៧.៥៤៥ | ៤.៦៤១.៨២០ | ៧៥៦.២១៤ | ៣.០៨១.៥៧២ |
| **អ្សូ ហ្វាយនែនខប ផនសប** | **ក្រុមហ៊ុនដែលអភិបាលមានភាគកម្ម** | | | | |
| សមតុល្យជំពាក់ពី | | ៣៧.៨៤៥ | ១៥៣.០៨៣ | ៤៤៩.៥៦៥ | ១.៨៣១.៩៧៧ |
| សមតុល្យជំពាក់ទៅ | | - | - | ១.៨៥៨ | ៧.៥៧១ |

សមតុល្យជំពាក់ពី ឬជំពាក់ទៅសម្ព័ន្ធញាតិមិនមានទ្រព្យបញ្ចាំ មិនមានការប្រាក់ និងសងតាមតម្រូវការ។

## ២២ ភតិសន្យា

### កិច្ចសន្យាភតិសន្យាប្រតិបត្តិការ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| ក្នុងរយៈពេល១ឆ្នាំ | ៣៣.៣៣៣ | ១៣៥.៩០០ | ១៦.៦៦៧ | ៦៧.៩៣៥ |
| ពី១ ទៅ ៥ឆ្នាំ | ១៣.៨៨៩ | ៥៦.៦២៥ | - | - |
| | ៤៧.២២២ | ១៩២.៥២៥ | ១៦.៦៦៧ | ៦៧.៩៣៥ |

## ២៣ ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

គោលការណ៍ណែនាំ និងគោលនយោបាយដែលបានអនុវត្តដោយក្រុមហ៊ុន ដើម្បីចាត់ចែងនូវហានិភ័យដែលកើតឡើងក្នុងសកម្មភាពអាជីវកម្មមានដូចខាងក្រោម៖

### (ក) ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យនៃការខាតបង់ប្រាក់ចំណូល និងការខាតបង់លើប្រាក់ដើមក្នុងទម្រង់ជាសំវិធានធនជាក់លាក់ ដោយសារការមិនទូទាត់សងបំណុលរបស់អ្នកខ្ចី ឬដៃគូរពាណិជ្ជកម្ម តាមរយៈការផ្តល់ឥណទាន និងសកម្មភាពវិនិយោគ។

កត្តាចម្បង ដែលនាំឱ្យមានហានិភ័យឥណទាន កើតចេញតាមរយៈឥណទានផ្តល់ដល់អតិថិជន។ ចំនួនហានិភ័យឥណទាននេះ ត្រូវបានបង្ហាញជាតម្លៃយោងរបស់ទ្រព្យសកម្មនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ សកម្មភាពឥណទានត្រូវបានណែនាំដោយគោលនយោបាយឥណទាន ដើម្បីធានាថាគោលបំណងទូទៅក្នុងការ ឱ្យខ្ចីបានសម្រេចជោគជ័យ។ ឧទាហរណ៍ សំពៀតឥណទានមានគុណភាពល្អ ហើយហានិភ័យឥណទានត្រូវបានបែងចែកយ៉ាងល្អ។ គោលនយោបាយផ្តល់ឥណទានបានបញ្ចូលនូវគោលនយោបាយផ្តល់កម្ចី គោលនយោបាយទ្រព្យបញ្ចាំ និងដំណើរការអនុម័តឥណទានដែលត្រូវអនុវត្ត ដើម្បីកាត់បន្ថយនូវហានិភ័យឥណទាន និងដើម្បីធានាថាបានអនុលោមតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

ក្រុមហ៊ុនបានរក្សាទ្រព្យបញ្ចាំ សម្រាប់ធានាដល់ឥណទានផ្តល់ដល់អតិថិជនតាមទម្រង់ជាសិទ្ធិលើទ្រព្យបញ្ចាំ និងអ្នកធានា។ ការប៉ាន់តម្លៃសមស្របគឺផ្អែកលើតម្លៃទ្រព្យបញ្ចាំដែលបានវាយតម្លៃនៅពេលឱ្យខ្ចី ហើយជាទូទៅមិនមានការកែប្រែឡើយ លើកលែងតែនៅពេលមានព្រឹត្តិការណ៍សំខាន់ណាមួយ ដែលអាចប៉ះពាល់ដល់តំបន់ ឬស្ថានភាពរបស់ទ្រព្យបញ្ចាំនោះ។

#### (i) ការវាស់វែងហានិភ័យឥណទាន

ក្រុមហ៊ុន វាយតម្លៃនូវកម្រិតប្រហែលនៃការខកខានមិនបានទូទាត់សងបំណុលរបស់អ្នកខ្ចីម្នាក់ៗ តាមរយៈការដោយផ្តោតលើស្ថានភាពប្រាក់ចំណេញនិងលំហូរសាច់ប្រាក់។ គណៈកម្មការឥណទាន គឺជាអ្នកទទួលខុសត្រូវក្នុងការអនុម័តលើឥណទានផ្តល់ដល់អតិថិជន។





#### (ii) គោលនយោបាយនៃការគ្រប់គ្រងកម្រិតហានិភ័យ និងបញ្ចៀសហានិភ័យ

ក្រុមហ៊ុនគ្រប់គ្រងកម្រិត និងត្រួតពិនិត្យការប្រមូលផ្តុំហានិភ័យឥណទាននៅពេលដែលហានិភ័យនោះត្រូវបានរកឃើញ។ ក្រុមហ៊ុនប្រើប្រាស់គោលនយោបាយ និងការអនុវត្តជាច្រើន ដើម្បីបញ្ចៀសហានិភ័យឥណទាន។ គោលនយោបាយដែលមានប្រសិទ្ធភាពបំផុតក្នុងចំណោមគោលនយោបាយទាំងអស់នេះ គឺការធានាដោយយកវត្ថុបញ្ចាំពីអតិថិជនដែលជាការអនុវត្តទូទៅមួយ។ ក្រុមហ៊ុនអនុវត្តតាមគោលការណ៍ណែនាំស្តីពីការទទួលយកនូវប្រភេទវត្ថុបញ្ចាំ ឬការបញ្ចៀសហានិភ័យឥណទាន។ ប្រភេទនៃវត្ថុបញ្ចាំសំខាន់ៗ ដែលបានធានាលើឥណទាន ផ្តល់ដល់អតិថិជនមានដូចជា៖

- វត្ថុបញ្ចាំជាទ្រព្យសម្បត្តិទាក់ទិននឹងលំនៅដ្ឋាន( មានដី អគារ និងទ្រព្យផ្សេងៗ) និង
- ការដាក់បញ្ចាំនូវទ្រព្យសកម្មអាជីវកម្មផ្សេងៗ ដូចជាដី និងអគារជាដើម។

#### (iii) គោលនយោបាយក្នុងការកំណត់ឱនភាពនៃតម្លៃ និងការធ្វើសំវិធានធន

ក្រុមហ៊ុនតម្រូវឱ្យអនុវត្តតាមការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ដែលអនុលោមតាមប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ និង ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការធ្វើចំណាត់ថ្នាក់ ឥណទាន និងសំវិធានធន។ សូមមើលកំណត់សំគាល់លេខ៣ (ច) សម្រាប់ព័ត៌មានលម្អិត។

| ការប្រឈមនឹងហានិភ័យឥណទាន | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| ឥណទានផ្តល់ដល់អតិថិជន | | | | |
| ឥណទានមិនទាន់ហួសកាលកំណត់ និងមិនមានឱនភាព | ៣.១២៨.២៣០ | ១២.៦៥៣.៦៩១ | ៤.៩០០.៥៤២ | ១៩.៩៦៩.៧០៩ |
| ឥណទានហួសកាលកំណត់តែមិនទាន់មានឱនភាព | ៣២៧.៧៩៧ | ១.៣២៥.៩៣៩ | ៧៤.៣៦៦ | ៣០៣.០៤១ |
| ឱនភាពតម្លៃបុគ្គល | ៤៧៧.២៦៦ | ១.៩៣០.៥៤១ | - | - |
| | ៣.៩៣៣.២៩៣ | ១៥.៩១០.១៧១ | ៤.៩៧៤.៩០៨ | ២០.២៧២.៧៥០ |

វាមិនសមហេតុផលទេក្នុងការទទួលបានតម្លៃសមស្របនៃវត្ថុបញ្ចាំដោយសារតែការចំណាយលើការទទួលបានព័ត៌មានបែបនេះមានច្រើនជាងផលប្រយោជន៍សក្តានុពល។ នៅក្រោមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា តម្លៃនៃវត្ថុបញ្ចាំមិនត្រូវបានគេយកមកពិចារណាទេនៅពេលកំណត់សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ។

#### ឥណទានមិនទាន់ហួសកាលកំណត់ និងមិនមានឱនភាព

ប្រាក់កម្ចីដល់អតិថិជនដែលមិនមានរយៈពេលលើសពី ៣០ថ្ងៃមិនត្រូវបានចាត់ទុកថាមានភាពឱនភាពទេលើកលែងតែព័ត៌មានផ្សេងទៀតអាចបង្ហាញបានផ្ទុយពីនេះ។

### ឱនភាពឥណទានទៅអតិថិជន

អនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យត្រូវបានធ្វើឡើងសម្រាប់កម្ចីដល់អតិថិជនដែលមានការទូទាត់ហួសកាលកំណត់ស្មើ ឬលើសពី ៩០ថ្ងៃសម្រាប់ប្រាក់កម្ចីរយៈពេលវែង (ស្មើ ឬច្រើនជាង ៦០ ថ្ងៃសម្រាប់កម្ចីរយៈពេលខ្លី) ។

### ឥណទានដែលហួសកាលកំណត់ប៉ុន្តែមិនមានឱនភាព

ឥណទានដែលហួសកាលកំណត់ប៉ុន្តែមិនថយចុះតម្លៃត្រូវបានចាត់ថ្នាក់ជាឥណទានឃ្លាំមើល ដោយអនុលោមតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ដែលមានសំវិធានធនជាក់លាក់ចំនួន ៣% នៃប្រាក់កម្ចីដែលនៅសល់។ ចំពោះប្រាក់កម្ចីទាំងនោះ ការប្រាក់តាមកិច្ចសន្យាឬការសងប្រាក់ដើមមានចំនួនលើសពី ៣០ថ្ងៃប៉ុន្តែតិចជាង ៩០ថ្ងៃសម្រាប់ប្រាក់កម្ចីរយៈពេលវែង (ច្រើនជាង ៣០ថ្ងៃប៉ុន្តែតិចជាង ៦០ថ្ងៃសម្រាប់ប្រាក់កម្ចីរយៈពេលខ្លី) លើកលែងតែមានព័ត៌មានផ្សេងទៀតដែលអាចបញ្ជាក់បាន។

### (ខ) ហានិភ័យប្រតិបត្តិការ

ការខាតបង់ពីហានិភ័យប្រតិបត្តិការ ដែលអាចកើតមានឡើងដោយសារតែកង្វះខាត ឬបរាជ័យនៃដំណើរការផ្ទៃក្នុងធនធានមនុស្ស និងប្រព័ន្ធ ឬបណ្តាលមកពីកត្តាខាងក្រៅ ត្រូវបានគ្រប់គ្រងតាមរយៈដំណើរការគ្រប់គ្រងហានិភ័យប្រតិបត្តិការ ដែលបានបង្កើតរួចហើយ ការត្រួតពិនិត្យ និងការរាយការណ៍ឱ្យបានត្រឹមត្រូវពីសកម្មភាពអាជីវកម្ម ធ្វើឡើងដោយផ្នែកត្រួតពិនិត្យ និងគាំទ្រដែលឯករាជ្យពីផ្នែក អាជីវកម្ម និងការត្រួតពិនិត្យដែលផ្តល់ដោយអ្នកគ្រប់គ្រង។

ការគ្រប់គ្រងលើហានិភ័យប្រតិបត្តិការ តម្រូវឱ្យបង្កើតនូវរចនាសម្ព័ន្ធ តួនាទី និងគោលនយោបាយត្រួតពិនិត្យច្បាស់លាស់មួយ។ គោលនយោបាយ និងវិធានការត្រួតពិនិត្យផ្ទៃក្នុងនីមួយៗត្រូវបានអនុវត្ត។ វិធានទាំងនេះរួមមានការបង្កើតនូវសិទ្ធិអំណាចក្នុងការចុះហត្ថលេខា ការកំណត់ប្រព័ន្ធត្រួតពិនិត្យការរៀបចំនូវនីតិវិធី និងឯកសារសំអាង។ ទាំងនេះត្រូវត្រួតពិនិត្យឡើងវិញជាបន្តបន្ទាប់ដើម្បីឆ្លើយតបទៅនឹងហានិភ័យប្រតិបត្តិការអាជីវកម្មមីក្រូហិរញ្ញវត្ថុ។

### (គ) ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ គឺជាហានិភ័យនៃការខាតបង់កើតពីការប្រែប្រួលមិនអំណោយផលនៅក្នុងកម្រិតតម្លៃ ឬអត្រាទីផ្សារដែលមានសមាសធាតុសំខាន់ពីរ គឺហានិភ័យរូបិយប័ណ្ណបរទេស និងហានិភ័យអត្រាការប្រាក់។ហានិភ័យទីផ្សារកើតចេញពីសកម្មភាពជួញដូរ ត្រូវបានគ្រប់គ្រងដោយការកំណត់នូវទីផ្សារសម្រាប់ស្ថានភាពជួញដូរធៀបនឹងកម្រិតហានិភ័យទីផ្សារដែលបានកំណត់ទុកជាមុន។

#### (i) ហានិភ័យរូបិយប័ណ្ណបរទេស

**ការផ្តោតលើហានិភ័យរូបិយប័ណ្ណ**

ប្រាក់ចំណូលជាចម្បងរបស់ក្រុមហ៊ុន ទទួលបានជាប្រាក់ដុល្លារអាមេរិក។ ចំណាយជាចម្បងរបស់ក្រុមហ៊ុន ត្រូវបានទូទាត់ជាប្រាក់ដុល្លារអាមេរិក។ ដូច្នេះក្រុមហ៊ុនមិនមានការផ្តោតលើហានិភ័យរូបិយប័ណ្ណជាសារវន្តឡើយ។

ចំនួនសរុបនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ តាមរូបិយប័ណ្ណ មានដូចខាងក្រោម៖





| នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២០ | ដុល្លារអាមេរិក | សមមូលនឹងដុល្លារអាមេរិក សមតុល្យពាន់រៀល | ដុល្លារអាមេរិក | សរុប គិតជាពាន់រៀល |
|---|---|---|---|---|
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | (កំណត់សម្គាល់៣.២) |
| សាច់ប្រាក់ក្នុងដៃ | ៧.១៥៧ | - | ៧.១៥៧ | ២៨.៩៥០ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | ៧.៥១៧ | - | ៧.៥១៧ | ៣០.៤០៦ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា | ១.៦២១.២២០ | - | ១.៦២១.២២០ | ៦.៥៥៧.៨៣៥ |
| ឥណទានផ្តល់ដល់អតិថិជន | ៣.៨៧៨.៣៥៨ | ៥៤.៩៣៥ | ៣.៩៣៣.២៩៣ | ១៥.៩១០.១៧១ |
| ទ្រព្យសកម្មផ្សេងៗ* | ១.១៦៧.៨៥៧ | - | ១.១៦៧.៨៥៧ | ៤.៧២៣.៩៨២ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | **៦.៦៨២.១០៩** | **៥៤.៩៣៥** | **៦.៧៣៧.០៤៤** | **២៧.២៥១.៣៨៤** |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| បំណុលផ្សេងៗ** | ១.២៣៩.៦១៤ | - | ១.២៣៩.៦១៤ | ៥.០១៤.២៣៩ |
| បំណុលហិរញ្ញវត្ថុសរុប | ១.២៣៩.៦១៤ | - | ១.២៣៩.៦១៤ | ៥.០១៤.២៣៩ |
| **ស្ថានភាពទ្រព្យសកម្មសុទ្ធ** | **៥.៤៤២.៤៩៥** | **៥៤.៩៣៥** | **៥.៤៩៧.៤៣០** | **២២.២៣៧.១០៥** |
| **នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៩** | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| សាច់ប្រាក់ក្នុងដៃ | ១៣.៦៨៧ | ១.៥០៧ | ១៥.១៩៤ | ៦១.៩១៦ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | ៦.៥៤៣ | - | ៦.៥៤៣ | ២៦.៦៦៣ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា | ៤៩៣.៥៤៨ | - | ៤៩៣.៥៤៨ | ២.០១១.២០៨ |
| ឥណទានផ្តល់ដល់អតិថិជន | ៤.៩៧៤.៩០៨ | - | ៤.៩៧៤.៩០៨ | ២០.២៧២.៧៥០ |
| ទ្រព្យសកម្មផ្សេងៗ* | ១.០៩៤.១៨២ | - | ១.០៩៤.១៨២ | ៤.៤៥៨.៧៩២ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | **៦.៥៨២.៨៦៨** | **១.៥០៧** | **៦.៥៨៤.៣៧៥** | **២៦.៨៣១.៣២៩** |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| បំណុលផ្សេងៗ** | ៨៩៧.៣០៥ | - | ៨៩៧.៣០៥ | ៣.៦៥៦.៥១៨ |
| បំណុលហិរញ្ញវត្ថុសរុប | ៨៩៧.៣០៥ | - | ៨៩៧.៣០៥ | ៣.៦៥៦.៥១៨ |
| **ស្ថានភាពទ្រព្យសកម្មសុទ្ធ** | **៥.៦៨៥.៥៦៣** | **១.៥០៧** | **៥.៦៨៧.០៧០** | **២៣.១៧៤.៨១១** |

* ចំនួនទឹកប្រាក់មិនរាប់បញ្ចូលប្រាក់បញ្ញើ និងការទូទាត់ជាមុន។

** ចំនួនទឹកប្រាក់ដែលមិនរាប់បញ្ចូលប្រាក់បញ្ញើរបស់អតិថិជន និងពន្ធដែលត្រូវបង់។

#### (ii) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺសំដៅទៅលើអស្ថេរភាពនៃចំណូលការប្រាក់សុទ្ធ ដោយសារការប្រែប្រួលនូវកម្រិតអត្រាការប្រាក់ និងការផ្លាស់ប្តូរនៅក្នុងសមាសភាពនៃទ្រព្យសកម្ម និងបំណុល។ ការកើតឡើងនូវហានិភ័យអត្រាការប្រាក់ គឺមានទំនាក់ទំនងជាចម្បងទៅលើឥណទាន ប្រាក់បញ្ញើនៅធនាគារនិងប្រាក់កម្ចី។

ដោយសារតែទ្រព្យសកម្មហិរញ្ញវត្ថុភាគច្រើនមានរយៈពេលខ្លី ហើយអត្រាការប្រាក់មានការផ្លាស់ប្តូរតាមអត្រាទីផ្សារ ក្រុមហ៊ុនមិនបានប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុសម្រាប់ការទប់ស្កាត់នូវហានិភ័យអត្រាការប្រាក់នេះទេ។

តារាងខាងក្រោមសង្ខេបពីការប្រឈមនឹងហានិភ័យអត្រាការប្រាក់របស់ក្រុមហ៊ុន។ តារាងនេះបង្ហាញពីរយៈពេលដែលឧបករណ៍ហិរញ្ញវត្ថុត្រូវកំណត់តម្លៃឡើងវិញ ឬដល់កាលកំណត់មួយណាដែលឆាប់ជាង។

| | រយៈពេលកំណត់សង | | | | | ពុំមានបម្រែ | |
|---|---|---|---|---|---|---|---|
| | រហូតដល់១ខែ | ពី១ខែ ដល់៣ខែ | ពី៣ខែ ដល់១២ខែ | ពី១ឆ្នាំ ដល់៥ឆ្នាំ | លើសពី៥ឆ្នាំ | បម្រួលការប្រាក់ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២០** | | | | | | | |
| **ទ្រព្យសកម្ម** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | - | - | ៧.១៥៧ | ៧.១៥៧ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | - | - | - | - | - | ៧.៥១៧ | ៧.៥១៧ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនានា | - | - | - | - | - | ១.៦២១.២២០ | ១.៦២១.២២០ |
| ឥណទានផ្តល់ដល់អតិថិជន | - | - | - | ៧៨២.៨៨៤ | ៣.១៥០.៨០៩ | - | ៣.៩៣៣.២៩៣ |
| ទ្រព្យសកម្មផ្សេងៗ* | ១.១៦៧.៨៥៧ | - | - | - | - | - | ១.១៦៧.៨៥៧ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | ១.១៦៧.៨៥៧ | | | ៧៨២.៨៨៤ | ៣.១៥០.៨០៩ | ១.៦៣៥.៨៩៤ | ៦.៧៣៧.០៤៤ |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | |
| បំណុលផ្សេងៗ** | - | - | - | - | - | ១.២៣៩.៦១៤ | ១.២៣៩.៦១៤ |
| **ប្រាក់កម្ចីហិរញ្ញវត្ថុសរុប** | - | - | - | - | - | ១.២៣៩.៦១៤ | ១.២៣៩.៦១៤ |
| **បម្រែបម្រួលការប្រាក់សរុប** | ១.១៦៧.៨៥៧ | - | - | ៧៨២.៨៨៤ | ៣.១៥០.៨០៩ | ៣៩៦.២៨០ | ៥.៤៩៧.៤៣០ |
| **សមមូលនឹងពាន់រៀល (កំណត់សម្គាល់៣.២)** | ៤.៧២៣.៩៨២ | - | - | ៣.១៦៦.៧៦៦ | ១២.៧៤៣.៤០៤ | ១.៦៩២.៩៥៣ | ២២.២៣៧.១០៥ |

* ចំនួនទឹកប្រាក់មិនរាប់បញ្ចូលប្រាក់បញ្ញើ និងការទូទាត់ជាមុន។

** ចំនួនទឹកប្រាក់ដែលមិនរាប់បញ្ចូលប្រាក់បញ្ញើរបស់អតិថិជន និងពន្ធដែលត្រូវបង់។

| | រយៈពេលកំណត់សង | | | | | ពុំមានបម្រែ | |
|---|---|---|---|---|---|---|---|
| | រហូតដល់១ខែ | ពី១ខែ ដល់៣ខែ | ពី៣ខែ ដល់១២ខែ | ពី១ឆ្នាំ ដល់៥ឆ្នាំ | លើសពី៥ឆ្នាំ | បម្រួលការប្រាក់ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៩** | | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | - | - | ១៥.១៩៤ | ១៥.១៩៤ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | - | - | - | - | - | ៦.៥៤៣ | ៦.៥៤៣ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនានា | - | - | - | - | - | ៤៩៣.៥៤៨ | ៤៩៣.៥៤៨ |
| ឥណទានផ្តល់ដល់អតិថិជន | ៨.៤៧៧ | ៤.៨០១ | ៨២.៨៨៣ | ១.៦២៦.៨០៥ | ៣.២៥១.៩៤២ | - | ៤.៩៧៤.៥០៨ |
| ទ្រព្យសកម្មផ្សេងៗ* | ១.០៩៤.១៨២ | - | - | - | - | - | ១.០៩៤.១៨២ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | ១.១០២.៦៥៩ | ៤.៨០១ | ៨២.៨៨៣ | ១.៦២៦.៨០៥ | ៣.២៥១.៩៤២ | ៥១៥.២៨៥ | ៦.៥៨៤.៣៧៥ |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | |
| បំណុលផ្សេងៗ** | - | - | - | - | - | ៨៩៧.៣០៥ | ៨៩៧.៣០៥ |
| **ប្រាក់កម្ចីហិរញ្ញវត្ថុសរុប** | - | - | - | - | - | ៨៩៧.៣០៥ | ៨៩៧.៣០៥ |
| **បម្រែបម្រួលការប្រាក់សរុប** | ១.១០២.៦៥៩ | ៤.៨០១ | ៨២.៨៨៣ | ១.៦២៦.៨០៥ | ៣.២៥១.៩៤២ | (៣៨២.០២០) | ៥.៦៨៧.០៧០ |
| **សមមូលនឹងពាន់រៀល (កំណត់សម្គាល់៣.២)** | ៤.៤៩៣.៣៣៥ | ១៩.៥៦៤ | ៣៣៧.៧៤៨ | ៦.៦២៩.២៣១ | ១៣.២៥១.៦៦៥ | (១.៥៥៦.៧៣២) | ២៣.១៧៤.៨១១ |

ការវិភាគរំញោចតម្លៃសមស្របសម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ថេរ

ក្រុមហ៊ុនមិនបានកត់ត្រាទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលមានអត្រាការប្រាក់ថេរតាមតម្លៃសមស្របនៅក្នុងរបាយការណ៍ចំណេញ ឬខាតនោះទេ។ ដូច្នេះ ការផ្លាស់ប្តូរអត្រាការប្រាក់នាចុងកាលបរិច្ឆេទ ពុំមានផលប៉ះពាល់ដល់ប្រាក់ចំណេញ ឬខាតនោះទេ។

ការវិភាគរំញោចលើលំហូរសាច់ប្រាក់សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ថេរ

ក្រុមហ៊ុនពុំមានឧបករណ៍ហិរញ្ញវត្ថុ ដែលមានអត្រាការប្រាក់អថេរនោះទេ។ ដូច្នេះ ការវិភាគរំញោចលើលំហូរសាច់ប្រាក់សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាការប្រាក់អថេរ មិនត្រូវបានបង្ហាញឡើយ។

### (ឃ) ហានិភ័យសាច់ប្រាក់ងាយស្រួល

ហានិភ័យសាច់ប្រាក់ងាយស្រួល គឺជាហានិភ័យដែលក្រុមហ៊ុនមិនមានលទ្ធភាពដើម្បីបំពេញកាតព្វកិច្ចសងបំណុល ទាក់ទិននឹងបំណុលហិរញ្ញវត្ថុរបស់ខ្លួននៅពេលដល់ថ្ងៃកំណត់សង និងមិនមានលទ្ធភាពបំពេញមូលនិធិវិញបាន នៅពេលដែលបានដកយកមកប្រើប្រាស់រួចហើយ។ ផលវិបាកនេះ អាចធ្វើឱ្យក្រុមហ៊ុនមិនមានសមត្ថភាពក្នុងការសងបំណុលដល់អ្នកផ្ញើប្រាក់ និងបំពេញកិច្ចសន្យា ឱ្យអ្នកខ្ចីប្រាក់។

#### (i) ដំណើរការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល

គណៈគ្រប់គ្រងក្រុមហ៊ុនតាមដានសាច់ប្រាក់ងាយស្រួលក្នុងតារាងតុល្យការ និងការគ្រប់គ្រងការប្រមូលផ្តុំទិន្នន័យនៃអាយុកាលបំណុល។ ការតាមដាននិងការធ្វើរបាយការណ៍ មានទម្រង់ជាការត្រួតពិនិត្យលើស្ថានភាពសាច់ប្រាក់ប្រចាំថ្ងៃ និងគម្រោងសម្រាប់ថ្ងៃ សប្តាហ៍ និងខែតាមលំដាប់រៀង ដោយសាររយៈពេលទាំងនេះជារយៈពេលសំខាន់ក្នុងការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល។ គណៈគ្រប់គ្រងត្រួតពិនិត្យបម្រែបម្រួលនៃអ្នកផ្ញើប្រាក់សំខាន់ៗ និងអ្នកខ្ចីប្រាក់ធំៗ និងប៉ាន់ស្មានពីការដកសាច់ប្រាក់របស់ពួកគេ។

បន្ថែមពីនេះ ក្រុមហ៊ុនត្រួតពិនិត្យយ៉ាងជិតដិតទៅលើទ្រព្យសកម្មនិងបំណុលដែលមានរំញោចលំហូរទឹកប្រាក់ ដោយប្រើប្រាស់ឧបករណ៍គ្រប់គ្រងទ្រព្យសកម្មនិងបំណុលដើម្បីព្យាករណ៍សាច់ប្រាក់ងាយស្រួល និងបញ្ចៀសហានិភ័យសាច់ប្រាក់ងាយស្រួល។

#### (ii) លំហូរសាច់ប្រាក់មិននិទស្សន៍

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៣.២) |
| គ្មានរយៈពេលថេរ | | | | |
| បំណុលផ្សេងៗ | ១.២៣៩.៦១៤ | ៥.០១៤.២៣៩ | ៨៩៧.៣០៥ | ៣.៦៥៦.៥១៨ |

### (ង) ការគ្រប់គ្រងដើមទុន

#### (i) បទប្បញ្ញត្តិដើមទុន

ចក្ខុវិស័យរបស់ក្រុមហ៊ុនក្នុងការគ្រប់គ្រងដើមទុន មានន័យទូលំទូលាយជាង "មូលធន" ដែលបង្ហាញក្នុងតារាងតុល្យការ។

ការគ្រប់គ្រងដើមទុនមានដូចខាងក្រោម ៖

- អនុលោមតាមតម្រូវការដើមទុនដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា
- ការពារលទ្ធភាពរបស់ក្រុមហ៊ុន ដើម្បីបន្តនិរន្តភាពអាជីវកម្ម ដូចនេះក្រុមហ៊ុន អាចបន្តផ្តល់ផលប្រយោជន៍ដល់ភាគទុនិក និងអត្ថប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធនឹងក្រុមហ៊ុន និង
- រក្សាមូលដ្ឋានដើមទុនរឹងមាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍អាជីវកម្ម។

ធនាគារជាតិនៃកម្ពុជាតម្រូវឱ្យគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ (i) បំពេញតាមតម្រូវការដើមទុនអប្បបរមានិង (ii) អនុលោមតាមសាធនភាព សាច់ប្រាក់ និងតម្រូវការផ្សេងទៀត។





#### (ii) ការបែងចែកដើមទុន

ការបែងចែកដើមទុនរវាងប្រតិបត្តិការ និងសកម្មភាពជាក់លាក់ គឺត្រូវបានគ្រប់គ្រងដោយកម្រិតភាគលាភដែលទទួលបានពីការបែងចែកនោះ។ ដើមទុនដែលបានបែងចែកទៅតាមប្រតិបត្តិការ ឬសកម្មភាពនីមួយៗ ត្រូវផ្អែកទៅតាមដើមទុនដែលកំណត់ដោយច្បាប់។

### ២៤ តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

តម្លៃសមស្រប សំដៅទៅលើតម្លៃដែលទ្រព្យសកម្មអាចត្រូវបានដោះដូរ ឬបំណុលអាចត្រូវបានទូទាត់តាមមូលដ្ឋានជំហោងដៃ។ ដោយសារតម្លៃទីផ្សារដែលអាចផ្ទៀងផ្ទាត់បាន មិនអាចរកបាន ដូច្នេះតម្លៃទីផ្សារសម្រាប់ផ្នែកសំខាន់នៃតម្លៃសមស្របរបស់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុនោះ មិនអាចរកបានទេ។ ហេតុនេះ តម្លៃសមស្របនេះមិនត្រូវបានបង្ហាញនោះទេ។

### ២៥ ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទរបាយការណ៍

ពុំមានព្រឹត្តិការណ៍ ដែលត្រូវកែសម្រួល ឬ ព្រឹត្តិការណ៍ពុំទាន់កែសម្រួលសំខាន់ៗណាមួយ បានកើតឡើងចន្លោះកាលបរិច្ឆេទនៃការរាយការណ៍ និងកាលបរិច្ឆេទនៃការអនុម័តអោយប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនោះទេ។

### ២៦ សេចក្តីអនុញ្ញាតិនៃរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ចុងការិយបរិច្ឆេទ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១។